مدرسة اهل البيت

صلوات الله عليهم

# សាលា
# អាហ្ល់លុល-បៃត៍

## សៀវភៅសិក្សា សីលធម៌ (أَخْلَاقٌ ) ថ្នាក់ទី ៤

(អាយុ ៨-៩ ឆ្នាំ)

قَالَ اَلنَّبِيُّ صَلَّى اللّٰهُ عَلَيْهِ وَ آلِهِ : طَلَبُ اَلْعِلْمِ فَرِيضَةٌ عَلَى كُلِّ مُسْلِمٍ وَ مُسْلِمَةٍ (بحار الأنوار ج ۱ ص ۱۷۷)

ព្រះសាស្ដាﷺមានព្រះវចនៈថា៖ "ស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចលើមុស្លីមប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា

មេរៀនទី ១ ចាំបាច់ត្រូវមានសីលធម៌.................................................................. ៥
មេរៀនទី ២ បែបបទនៅក្នុងអ៊ីមុាំបារ៉.................................................................. ៨
មេរៀនទី ៣ របៀបផឹក .................................................................. ១០
មេរៀនទី ៤ របៀបនិយាយ .................................................................. ១២
មេរៀនទី ៥ ដើម្បីសព្វព្រះហឫទ័យអល់ឡោះហ្ ﷻ តែម្យ៉ាង.................................................................. ១៤
មេរៀនទី ៦ គិតល្អអំពីអ្នកដទៃ .................................................................. ១៧
មេរៀនទី ៧ គោរពអ្នកដទៃ .................................................................. ២០
មេរៀនទី ៨ ព្យាយាមមិនលះ.................................................................. ២៤
មេរៀនទី ៩ ការច្រណែនឈ្នានីស .................................................................. ២៧
មេរៀនទី ១០ មិត្តភាព .................................................................. ៣០
មេរៀនទី ១១ មានចំណេះ.................................................................. ៣៣
មេរៀនទី ១២ ការអត់ធ្មត់ (صَبَر) .................................................................. ៣៦
មេរៀនទី ១៣ ចូរអនុវត្តិអ្វីដែលអ្នកថា .................................................................. ៤០
មេរៀនទី ១៤ គោរពពាក្យសន្យា.................................................................. ៤៣
មេរៀនទី ១៥ ប្រកាន់ខ្លួន.................................................................. ៤៦
មេរៀនទី ១៦ សូមខមាទោស (اَلتَّوْبَة) .................................................................. ៤៩
មេរៀនទី ១៧ លើកលែងទោសឲ្យអ្នកដទៃ .................................................................. ៥២
មេរៀនទី ១៨ ភាតរភាព-ឯកភាព .................................................................. ៥៥
មេរៀនទី ១៩ ត្រួតពិនិត្យខ្លួនឯង.................................................................. ៥៨
មេរៀនទី ២០ របៀបធ្វើដំណើរ .................................................................. ៦១

## មេរៀនទី ១

# ចាំបាច់ត្រូវមានសីលធម៌

ព្រះសាស្តា ﷺ មានព្រះវចនៈថា៖ "អល់ឡោះហ៏ عزوجل បានចាត់បញ្ជូនខ្ញុំ ﷺ មកដើម្បីបង្ហាត់បង្រៀនមនុស្សឲ្យចេះដឹងសីលធម៌ ។"

ហាឌីស្ហខាងលើនេះបញ្ជាក់ឲ្យដឹងថា ការមានសីលធម៌ល្អប្រសើរជាប្រការសំខាន់មួយក្នុងសាសនាអ៊ីស្លាម ។





ថ្ងៃមួយ មានបុរសម្នាក់បានមករក ព្រះសាស្តា ﷺ ទូលព្រះអង្គ عليه السلام ថា មាននារីម្នាក់ កាន់សីលត្រណមពេលថ្ងៃ បួងសួងអល់ឡោះហ៏ عزوجل ពេលយប់ តែគាត់ពុំមានសីលធម៌ទេ គាត់មានវាចាអាក្រក់ធ្វើឲ្យមនុស្សជុំវិញខ្លួនគាត់ឈឺចាប់ ។

ព្រះសាស្តា ﷺ មានព្រះវចនៈថានារីនេះពុំមានតម្លៃទេ គាត់នឹងចូលនរក ។

ព្រឹត្តិការណ៍ខាងលើនេះបញ្ជាក់ប្រាប់យើងថា ទង្វើល្អរបស់អ្នកពុំមានតម្លៃច្រើនទេបើគ្មានសីលធម៌ប្រសើរទេនោះ ។

អ៊ីម៉ាំយ៉ាក្កុំហ្វារ អាស្ស-ស្វ៏ឌិក្ក صلوات الله عليه والسلام មានវចនៈថា អ្នកណាមានសីលធម៌ប្រសើរ អ្នកនោះមានរង្វាន់ ស្មើនឹងអ្នកដែលចំណាយពេលកាន់សីលត្រណមពេលថ្ងៃ ចំណាយពេលស្វ៏ឡាត្តុំពេលយប់ ។

ព្រះសាស្តា ﷺ និងព្រះសន្តអ៊ីម៉ាំយើង عليهم السلام បានទាក់ទាញមនុស្សយ៉ាងច្រើនមកចូលសាសនាអ៊ីស្លាមអាស្រ័យសីលធម៌ល្អប្រសើររបស់ព្រះអង្គ عليهم السلام ។

ចូរចងចាំថា ពេលអ្នកមានឥរិយាបថអាក្រក់ចំពោះមុខសាធារណជន មនុស្សនឹងមិនថា "មើលចុះ ក្មេងប្រុស/ស្រីនេះមានមារយាទអាក្រក់" ទេ តែមនុស្សនឹងថា "មើលចុះ មុស្លីមប្រុស/ស្រីនេះមានមារយាទអាក្រក់"។ អ្នកមិនត្រឹមតែធ្វើឲ្យឪពុកម្តាយអ្នកបាក់មុខប៉ុណ្ណោះទេ អ្នកនឹងធ្វើឲ្យសាសនាអ៊ីស្លាមអាប់ឱនដែរ។

ពេលអ៊ីម៉ាំ ១២ របស់យើងនៅក្នុងកុយ់បាស្ញ (គឺកំបាំងខ្លួន) យើងទាំងអស់គ្នាត្រូវមើលថែរក្សាសាសនាអ៊ីស្លាម។

## លំហាត់ ១

ចូរសរសេរលេខឃ្លាក្នុងជួរត្រូវលើតារាងខាងក្រោមនេះ ។

| សីលធម៌ល្អប្រសើរ | សីលធម៌អាក្រក់ |
|---|---|
| | |

១. មនុស្សចាស់ឈរ អ្នកអង្គុយ ។
២. អ្នកគំនាប់មិត្តដោយឲ្យសាឡាម ។
៣. ពេលអ្នកឃើញគេធ្វើការ អ្នកជួយធ្វើដោយមិនបាច់ចាំឲ្យគេសូមឲ្យជួយ ។
៤. អ្នកអង្គុយសណ្ដូកជើងក្នុងម៉ាស់ជិុដ ។
៥. អ្នកស្រែកឆ្លើយតបសំណួរដោយមិនលើកដៃ ។
៦. គេចំអកឲ្យអ្នកណាម្នាក់ អ្នកស្ដាប់ដោយមិនថាអ្វីឡើយ ។
៧. ទាំងអស់គ្នាអង្គុយដើម្បីបរិភោគ អ្នកជួសបាយមកបរិភោគមុនគេ ។
៨. មនុស្សចាស់ជាងអ្នកលីសែងរបស់ធ្ងន់ អ្នកជួយលីសែងគាត់ ។
៩. ម្ដាយអ្នកសូមឲ្យអ្នកជួយធ្វើការនីមួយ ពេលអ្នកកំពុងជក់ចិត្តមើលទូរទស្សន៍ ។ អ្នកធ្វើការនោះដោយធ្វើឲ្យគាត់ដឹងថាអ្នកមិនពេញចិត្ត ។
១០. អ្នកជិតនឹងហូបស្ករគ្រាប់ដែលអ្នកចូលចិត្ត ពេលអ្នកឃើញគេមើលមកអ្នក ។ អ្នកឲ្យស្ករគ្រាប់នោះទៅអ្នកនោះ ។

## មេរៀនទី ២

# បែបបទនៅក្នុងអ៊ីម៉ាំបារ៉

មជ្ឈមណ្ឌលអ៊ីស្លាមមិនមែនម៉ាស់ឃ្ញិដ្ទេ តែជាអ៊ីម៉ាំបារ៉ (امامبارا ឬ ហ៊ូសៃនីយ៉ាស្ហ់ اَلْحُسَيْنِيَّة) ។

ម៉ាស់ឃ្ញិដ្ជាកន្លែងសម្រាប់ស្ហ៍ឡាត្ហ់ ។

អ៊ីម៉ាំបារ៉ជាកន្លែងសម្រាប់ស្ហ៍ឡាត្ហ់និងសម្រាប់បំពេញការងារច្រើនទៀត ។

អ្នកត្រូវចូលទៅក្នុងនោះដោយឈានជើងស្តាំមុន និងចូរដឹងថាអ្នកនៅកន្លែងណានិងចូរអនុវត្តិដោយសេចក្តីគោរពដែលសក្តិសមសម្រាប់កន្លែងបែបនេះ ។

ចូរថា اَلسَّلَامُ عَلَيْكُمْ ចំពោះបណ្តាអ្នកដែលអ្នកជួប កុំចាំឲ្យគេថាមុនអ្នក ។

បន្ទាប់ពីបានដោះស្បែកជើង ចូររកកន្លែងអង្គុយ ។

ចូរអង្គុយត្រង់ខ្លួន ។ ចូរកុំអង្គុយរបៀបក្រាបឬស្ប៉ាប ។ ចូរកុំអង្គុយសណ្តូកជើង ។ ចូរកុំអង្គុយផ្អែកនឹងជញ្ជាំង ។ ចូរកុំអង្គុយយកតែស្រួលម្នាក់ឯក ចំណែកឯអ្នកដទៃជ្រៀតគ្នា ។

ពេលគេនិយាយសុន្ទរកថា ចូរស្តាប់គេដោយយកចិត្តទុកដាក់ ។ ចូរកុំនិយាយគ្នាពេលគេសូត្រឃុត្ហ្បាស្ហ់ ពេលគេអាស្ហាន ពេលគេអ៊ីក្ហ៍ម៉ាស្ហ់ ពេលគេឌុអាអ៍ ឬ ពេលគេសូត្រផ្សេងៗទៀត ។

បើអ្នកមិនយល់គេថាអ្វីទេ ចូរសូត្រស្ហ៍ឡាវ៉ាត ឬ តាស់ប៊ីះហ្ហ៍ សៃយីដ្ហាស្ហ់ ហ្វាទីម៉ាស្ហ់ ស្ហាស្ហ់រ៉អ៊ ســلامالله عليها ។

ពេលគេចែកចំណី ចូររង់ចាំគេឲ្យ ហើយចូរយកតែមួយ ។

ពេលចាកចេញ ចូរចេញតាមសម្រួលដោយប្រយ័តប្រយែង កុំប៉ះទង្គិចអ្នកដទៃ ។ ចូរចាកចេញដោយឈានជើងឆ្វេងមុន ។

ចូរថា ហ៊្វី អាម៉ានីលឡាស្ហ់ (فِي أَمَانِ اَللَّهِ) ឬ ឃូដ្ហា ហ្ហាហ្វ៊ីស្ហ (خُدَا حَافِظ) ពេលអ្នកលាទៅវិញ ។

# លំហាត់ ២



ចូរសរសេរនៅក្នុងចន្លោះក្រោមរូបភាព នូវប្រការនានាដែលអ្នកមិនត្រូវធ្វើពេលអ្នកនៅក្នុងអ៊ីម៉ាំបារ៉ ។

## មេរៀនទី ៣

# របៀបផឹក

ពេលអ្នកផឹក ចូរកុំផឹកតែម្តង តែចូរផឹកដោយមាន ៣ ដំណាក់ ។ មុនផឹកចូរថា بِسْمِ اللهِ الرَّحْمٰنِ الرَّحِيمِ ហើយឈប់ផឹកហើយថា اَلْحَمْدُ لِلّٰهِ ។

ពោលគឺ ធ្វើដូចតទៅ៖

ថា "ប៊ិសមិលឡាស៊្ហ" ផឹក ឈប់ផឹក ថា "អាល់-ហ៊ាំឌូលិលឡាស៊្ហ" ។

ថា "ប៊ិសមិលឡាស៊្ហ" ផឹក ឈប់ផឹក ថា "អាល់-ហ៊ាំឌូលិលឡាស៊្ហ" ។

ថា "ប៊ិសមិលឡាស៊្ហ" ផឹក ឈប់ផឹក ថា "អាល់-ហ៊ាំឌូលិលឡាស៊្ហ" ។



ពេលអ្នកផឹកទឹក ចូរនឹកឃើញអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام និងគ្រួសារព្រះអង្គ صلوات الله عليه والسلام ដែលស្រេកទឹកនៅការបាឡាអ៊ ។ ពេលអ្នកផឹករួច ចូរសូមឲ្យអល់ឡោះហ្វ៍ عزّ وجلّ ប្រទានពរជ័យ ឲ្យអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام ឲ្យគ្រួសារព្រះអង្គ صلوات الله عليه والسلام និងឲ្យបណ្តាសាវកព្រះអង្គ صلوات الله عليه والسلام ហើយចូរដាក់បណ្តាសាពួកសត្រូវនិងពួកឃាតករព្រះអង្គ صلوات الله عليه والسلام ។

ចូរកុំផឹកក្នុងកែវប្រេះ បើអាចចៀសវាងបាន ។ បើអ្នកផឹកក្នុងកែវប្រេះ ចូរកុំផឹកលើកន្លែងប្រេះ ។ អ្នកមិនត្រូវផឹកលើកន្លែងមានដៃកែវទេ ។ ពេលថ្ងៃ ចូរឈរផឹក ។ ពេលយប់ ចូរអង្គុយផឹក ។ ចូរកុំផឹកច្រើនពេក ។ ពុំមានភេសជ្ជៈណាប្រសើរជាងទឹកទេ ។ សត្វលោកទាំងអស់របស់អល់ឡោះហ្វ៍ عزّ وجلّ សុទ្ធតែផឹកទឹកដើម្បីរស់រានមានជីវិត ។ អល់ឡោះហ្វ៍ عزّ وجلّ មានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាល់-អាន់ប៊ីយ៉ាអ៊ុ អាយ៉ាស៊្ហ ៣០ ថា៖

وَجَعَلْنَا مِنَ ٱلْمَآءِ كُلَّ شَىْءٍ حَىٍّ ۝٣٠

*៣០. ... យើងបានបង្កើតគ្រប់វត្ថុមានជីវិតមកពីទឹក... (២១:៣០)*

## លំហាត់ ៣

ចូរសរសេរនៅក្នុងរង្វង់ នូវប្រការនានាដែលអ្នកត្រូវគិតដល់ពេលអ្នកផឹកទឹក ។



**មេរៀនទី ៤**

# របៀបនិយាយ

អ្វីដែលធ្វើឲ្យយើងចាប់អារម្មណ៍សៀវភៅអានមុនគេគឺក្របវា បន្ទាប់មកយើងអានសៀវភៅនោះហើយយើងអាចសម្រេចចិត្តបាននៅទីបំផុត ។ ដូចគ្នាដែរ អ្វីដែលធ្វើឲ្យមនុស្សចាប់អារម្មណ៍អ្នកដំបូងបង្អស់នោះគឺអាការៈក្រៅរបស់អ្នក តែការយោបល់ផ្ដាច់ព្រ័ត្ររបស់មនុស្សនៅលើការនិយាយស្ដីរបស់អ្នក ។

ព្រះសាស្ដាអ៊ីសា عليه السلام មានព្រះវចនៈថាអ្នកត្រូវប្រៀបធៀបសម្ដីនឹងមាស ចូររង់ចាំពេលល្អដើម្បីនិយាយអ្វីដែលត្រូវនិយាយ ដូចពេលអ្នករង់ចាំឱកាសល្អដើម្បីចាយវាយមាសរបស់អ្នកនោះដែរ ។

ដូច្នេះចូរគិតសិនមុននឹងហើបមាត់និយាយ ចូរកុំបណ្ដោយឲ្យសម្ដីហូរចេញមកដោយឥតប្រយោជន៍ បណ្ដាលឲ្យគេមានយោបល់មិនល្អអំពីអ្នក ។

អ៊ីម៉ាំហ៊្វូសៃន៍ صلوات الله عليه والسلام មានវចនៈថា អ្នកមិនត្រូវចាប់ផ្ដើមសន្ទនាជាមួយអ្នកណាមួយមុនឲ្យសាឡាមអ្នកនោះជាដាច់ខាត ។

ឲ្យសាឡាមហើយចូរនិយាយតែអ្វីដែលមានប្រយោជន៍និងពិត ដែលមិនធ្វើឲ្យអ្នកដទៃឈឺចាប់ ។ ចូរកុំនិយាយបង្កាច់អ្នកដទៃ ចូរកុំនិយាយអាក្រក់អំពីអ្នកដទៃ ចូរកុំស្ដាប់អ្នកណាដែលនិយាយបង្កាច់គេ ចូរកុំស្ដាប់អ្នកណាដែលនិយាយអាក្រក់អំពីអ្នកដទៃ ។

ចូរកុំធ្វើឲ្យអ្នកដទៃឈឺចាប់ ទោះបីដោយនិយាយលេងក៏ដោយ ។ ចូរកុំប្រើសម្ដីអាសគ្រោមជាដាច់ខាត ។

មុននិយាយ ចូរអ្នកគិតសិនថាតើអ្នកគួរនិយាយអ្វីដែលអ្នកចង់និយាយនោះទេប្រសិនបើអ៊ីម៉ាំ ១២ របស់យើង صلوات الله عليه والسلام នៅក្បែរអ្នក ។ បើអ្នកមិនជឿជាក់ទេថាអ្វីដែលអ្នកចង់និយាយនោះជាប្រការល្អ ចូរចៀសវាងនិយាយ ។

## លំហាត់ ៤



មុននឹង




ចូរសរសេរនៅក្នុងខួរក្បាលប្រការនានាដែលអ្នកត្រូវគិតដល់ មុនហើបមាត់និយាយ ។

## មេរៀនទី ៥

# ដើម្បីសព្វព្រះហឫទ័យអល់ឡោះហ៍عز وجلតែម្យ៉ាង

អ្នកត្រូវធ្វើអ្វីៗដើម្បីផ្គាប់ចិត្តអល់ឡោះហ៍عز وجلតែម្យ៉ាង ។ មានតែធ្វើបែបនេះទេដែលអ្នកនឹងបានទទួលផលដែលអ្នកសមនឹងបាន ។

សម័យព្រះសាស្តាមូសាعليه السلام មានបុរសម្នាក់ដែលជឿស៊ប់ចិត្ត គាត់នឹកនាដល់អល់ឡោះហ៍عز وجلទាំងយប់ទាំងថ្ងៃ ។

ថ្ងៃមួយ គាត់បានឮគេនិយាយអំពីដើមឈើមួយដើមដែលមនុស្សគោរពបូជា ។ ដំណឹងនេះធ្វើឲ្យគាត់ក្រោធពេក គាត់ក៏ទៅរកដើមឈើនោះគិតនឹងកាប់វាចោល ។ លុះទៅដល់ដើមឈើនោះ ស្ហៃតនលعنه اللهចេញមកជួបគាត់ដោយក្លែងខ្លួនជាមនុស្សចាស់ ។ ស្ហៃតនលعنه اللهសួរគាត់ថាតើគាត់គិតធ្វើអ្វី ។ បុរសជឿស៊ប់ចិត្តបានឆ្លើយថាគាត់គិតកាប់ដើមឈើនោះចោលព្រោះមនុស្សគោរពសក្ការៈវា ។ ស្ហៃតនលعنه اللهសួរបុរសនោះថាបើអល់ឡោះហ៍عز وجلចង់កាប់ដើមឈើនេះចោលមែន តើព្រះអង្គعليه السلامគួរតែចាត់បញ្ជូនព្រះសាស្តាមួយអង្គមករំលំវាមែនទេ ? បុរសជឿស៊ប់ចិត្តមិនស្តាប់ស្ហៃតនលعنه اللهទេ ។ ទាំងពីរនាក់នេះឈ្លោះប្រកែកគ្នា លុះដល់ថ្នាក់វាយប្រតប់គ្នា ។ បុរសជឿស៊ប់ចិត្តផ្តួលស្ហៃតនលعنه اللهលើដីហើយអង្គុយពីលើវាلعنه الله ។ ស្ហៃតនលعنه اللهអង្វរបុរសនោះឲ្យលែងវាلعنه الله ហើយប្រាប់គាត់ថាវាلعنه اللهរកឃើញដំណោះស្រាយមួយដែលជួយបុរសនេះទាំងក្នុងលោកនេះនិងក្នុងលោកមុខ ។ បុរសនោះក៏ស្តាប់ស្ហៃតនលعنه الله ។ ស្ហៃតនលعنه اللهបាននិយាយបន្តថាវាلعنه اللهនឹងឲ្យបុរសនោះ ២ឌីណាររាល់ថ្ងៃ ។ គាត់អាចចាយវាយខ្លះបានសម្រាប់ខ្លួនឯង អាចជួយជនក្រីក្របានខ្លះ តែសូមឲ្យបុរសនោះកុំកាប់ដើមឈើទាល់តែអល់ឡោះហ៍عز وجلប្រាប់ឲ្យដឹងសិនថា តើត្រឹមត្រូវឬទេដែលកាប់ដើមឈើនោះចោល ។ បុរសជឿស៊ប់ចិត្តឆ្ងល់ស្ហៃតនលعنه الله ។ គាត់គិតថានេះជាគំនិតល្អ ហើយក៏យល់ស្របតាម ។

ថ្ងៃបន្ទាប់ បុរសជឿស៊ប់ចិត្តក្រោកពីដេក ឃើញប្រាក់ ២ ឌីណារនៅក្រោមខ្នើយ ។ គាត់សប្បាយចិត្ត បានចាយវាយប្រាក់នោះបន្តិចសម្រាប់ខ្លួនឯង បានឲ្យ

ជនក្រីក្របន្តិច ។ តែថ្ងៃបន្ទាប់មក គាត់មិនឃើញមានប្រាក់ទេ បណ្ដាលឲ្យគាត់ក្រោធ ។ គាត់ក៏បានលីពូថៅទៅកាប់ដើមឈើចោល ។

គាត់បានជួបស្ទៃតន្លលعنه الله ក្លែងខ្លួនជាមនុស្សចាស់នៅជិតដើមឈើនោះ វាلعنه الله សួរគាត់ថាមកធ្វើអ្វីកន្លែងនេះ ។ បុរសជឿស៊ប់ចិត្តឆ្លើយថាគាត់មកកាប់ដើមឈើចោល តែស្ទៃតន្លលعنه الله បានតបគាត់វិញថាគាត់ពុំមានសមត្ថភាពកាប់ដើមឈើនោះរួចទេ គាត់គួរតែត្រឡប់ទៅផ្ទះវិញល្អជាង ។

ទាំងពីរនាក់ក៏វាយប្រតប់គ្នាម្ដងទៀត តែលើកនេះស្ទៃតន្លលعنه الله ឈ្នះបុរសជឿស៊ប់ចិត្ត ។ បុរសនេះឆ្ងល់ណាស់ សួរស្ទៃតន្លលعنه الله ថាហេតុអ្វីគ្រាមុនគាត់ឈ្នះវាلعنه الله តែលើកនេះគាត់ចាញ់វាلعنه الله ? ស្ទៃតន្លលعنه الله បានតបថាលើកទីមួយបុរសនោះមកកាប់ដើមឈើចោលព្រោះតែស្រឡាញ់អល់ឡោះហ៍عز وجل តែម្យ៉ាង តែលើកទីពីរបុរសនោះមកព្រោះតែស្រឡាញ់ប្រាក់ ។

ឧត្ដមគតិរឿងនេះគឺ បើអ្នកធ្វើអ្វីមួយដើម្បីសព្វព្រះហឫទ័យអល់ឡោះហ៍عز وجل តែម្យ៉ាង អល់ឡោះហ៍عز وجل នឹងប្រទានឲ្យអ្នកនូវកម្លាំងពិសេសមួយដើម្បីបានសម្រេចគោលដៅ ។

# លំហាត់ ៥

ចូរសរសេរថាអ្វីកើតឡើងរាល់ដង ហេតុអ្វី ។

ក្នុងព្រះនាមអល់ឡោះហ្វ៍عز وجل





ក្នុងនាមប្រាក់





## មេរៀនទី ៦

# គិតល្អអំពីអ្នកដទៃ

អល់ឡោះហ៍ﷻមួយគត់ជាអ្នកសម្រេចសេចក្តី ព្រោះព្រះអង្គﷻឃើញនិងដឹងអ្វីៗទាំងអស់ ។

យើងមិនមានសិទ្ធិអារកាត់សេចក្តីវាយតម្លៃអ្នកដទៃទេ ទោះបីអ្នកនោះជាមុស្លីមឬមិនមែនមុស្លីមក៏ដោយ ។

អ៊ីម៉ាំស្ហៃនុល-អាប៊ីឌីនصلوات الله عليه والسلامមានវចនៈថា៖



"អ្នកត្រូវគិតល្អអំពីបុគ្គលដែលក្មេងជាងអ្នក ព្រោះបុគ្គលនោះមានពេលធ្វើប្រការអាក្រក់តិចជាងអ្នក ។"



"អ្នកត្រូវគិតល្អអំពីបុគ្គលដែលចាស់ជាងអ្នក ព្រោះអ្នកនោះមានពេលធ្វើប្រការល្អច្រើនជាងអ្នក ។"



"អ្នកត្រូវគិតល្អអំពីបុគ្គលតំណាលអ្នក ព្រោះអ្នកមិនដឹងថាបុគ្គលនោះបានធ្វើអ្វីខ្លះទេ តែអ្នកដឹងច្បាស់ថាខ្លួនអ្នកបានធ្វើប្រការល្អណាខ្លះ បានធ្វើប្រការអាក្រក់ណាខ្លះ ។"

ពាក្យពេជន៍ខាងលើនេះអប់រំយើងឲ្យចាំបាច់ចេះគិតល្អអំពីអ្នកដទៃជានិច្ច ។

ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامចូលចិត្តទទួលភ្ញៀវនៅផ្ទះព្រះអង្គعليه السلام ។ ព្រះអង្គដឹងថាទទួលភ្ញៀវនោះបានរង្វាន់ប៉ុណ្ណាខ្លះ ។ ព្រះអង្គعليه السلامចូលចិត្តទទួលអ្នកដំណើរឲ្យស្នាក់នៅផ្ទះព្រះអង្គعليه السلامដោយផ្តល់អាហារនិងកន្លែងសម្រាក ។ រៀងរាល់ព្រឹកព្រះអង្គعليه السلامរង់ចាំមើលអ្នកដំណើរ ឯក្បាលផ្លូវធំនៅក្បែរផ្ទះព្រះអង្គعليه السلام ដើម្បីអញ្ជើញពួកគាត់ទៅផ្ទះព្រះអង្គعليه السلام ។ ថ្ងៃមួយ ព្រះអង្គعليه السلامក្រៀមក្រំដែលពុំឃើញមានអ្នកដំណើរដើរកាត់តាមនោះ ៣ ថ្ងៃជាប់ៗគ្នា ។ ថ្ងៃទី ៤ បុរសចំណាស់

ម្នាក់បានឆ្លងកាត់តាមផ្លូវនោះ ។ ព្រះសាស្តាអ៊ីបរ៉ហ៊ីម عليه السلام រីករាយអនេក ក៏បានអញ្ជើញបុរសនោះទៅបរិភោគអាហារឯផ្ទះព្រះអង្គ عليه السلام ។ បុរសចំណាស់យល់ព្រម ។ ពេលអង្គុយបរិភោគ ព្រះសាស្តាអ៊ីបរ៉ហ៊ីម عليه السلام ថា "ប៊ិសមិលឡាស្ហ៍" មុនបរិភោគ តែបុរសចំណាស់មិនថាអ្វីទេ ។ ព្រះអង្គ عليه السلام សួរបុរសនោះថា ហេតុមិនចាប់ផ្តើម ដោយព្រះនាមអល់ឡោះហ៍ عز وجل ព្រោះអល់ឡោះហ៍ عز وجل ជាអ្នកផ្តល់នូវអាហារ ។ បុរសចំណាស់បានតបថា គាត់មិនជឿអល់ឡោះហ៍ عز وجل ទេ គាត់គោរពបូជាភ្លើង ។ ព្រះសាស្តាអ៊ីបរ៉ហ៊ីម عليه السلام ក្រោធណាស់ សូមឲ្យបុរសចំណាស់



ចេញពីផ្ទះព្រះអង្គ عليه السلام ភ្លាម ។ លុះបុរសចំណាស់ចេញពីផ្ទះភ្លាម ទេវតាយ៉ីបរ៉អ៊ីល عليه السلام មកជួបព្រះសាស្តាអ៊ីបរ៉ហ៊ីម عليه السلام ក្នុងព្រះនាមអល់ឡោះហ៍ عز وجل ប្រាប់ព្រះអង្គ عليه السلام ថាអល់ឡោះហ៍ عز وجل បានចិញ្ចឹមបុរសឥតជំនឿនេះអស់រយៈពេល ៧០ ឆ្នាំហើយ ។ ម្តេចក៏ព្រះសាស្តាអ៊ីបរ៉ហ៊ីម عليه السلام មិនអាចអត់ទ្រាំផ្តល់អាហារ មួយពេលដល់បុរសនោះបាន ?

ព្រះសាស្តាអ៊ីបរ៉ហ៊ីម عليه السلام សោកស្តាយណាស់ រត់ទៅតាមបុរសចំណាស់ អង្វរសូមគាត់ត្រឡប់មកផ្ទះព្រះអង្គ عليه السلام វិញដើម្បីទទួលទានបាយជុំគ្នា ។

ឧត្តមគតិរឿងនេះគឺ៖

១) ចូរកុំអារកាត់វាយតម្លៃអ្នកដទៃ មានតែអល់ឡោះហ៍ عز وجل មួយគត់ដែលមានសមត្ថភាពធ្វើបែបនេះ ។

២) ទាំងអស់គ្នាសុទ្ធតែមានសិទ្ធិ មុស្លីមក្តី មិនមែនមុស្លីមក្តី ។

៣) អល់ឡោះហ៍ عز وجل ទ្រង់សព្វព្រះហឫទ័យពេលអ្នកមើលថែរក្សាភ្ញៀវ ។

## លំហាត់ ៦

ចូរសរសេរសម្ដីរបស់អ៊ីម៉ាំស្សៃនុល-អាប៊ីឌីន صلوات الله عليه والسلام គឺ៖ អ្នកត្រូវគិតល្អអំពីអ្នកដទៃដែល៖

១) ក្មេងជាងអ្នកព្រោះ________________________________



២) ចាស់ជាងអ្នកព្រោះ________________________________



៣) តំណាលអ្នកព្រោះ________________________________



**មេរៀនទី ៧**

# គោរពអ្នកដទៃ

អល់ឡោះហ៍ﷻមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាល់-ហ៊ូយ៉ូរ៉ត អាយ៉ាស់ ១១ ថា៖

يَٰٓأَيُّهَا ٱلَّذِينَ ءَامَنُواْ لَا يَسۡخَرۡ قَوۡمٞ مِّن قَوۡمٍ عَسَىٰٓ أَن يَكُونُواْ خَيۡرٗا مِّنۡهُمۡ ﴿١١﴾

*១១. បណ្ដាអ្នកមានសទ្ធាអើយ ចូរកុំឲ្យមនុស្សក្រុមណាមួយចំអកឲ្យមនុស្សមួយក្រុមទៀត ។ ជួនកាលពួកគេអាចប្រសើរជាងពួកគេទាំងនោះ ។*(៤៩:១១)

សាសនាអ៊ីស្លាមអប់រំយើងឲ្យចេះគោរពគ្នាទៅវិញទៅមក មិនឲ្យគិតថាយើងប្រសើរជាងអ្នកឯទៀតទេ ព្រោះមានតែអល់ឡោះហ៍ﷻទេដែលអាចអារកាត់សេចក្ដីបាន ។

ថ្ងៃមួយព្រះសាស្ដាﷺអង្គុយម្នាក់ឯងនៅឯម៉ាស់យ៉ិដ្ឋ បុរសម្នាក់បានចូលមកក្បែរព្រះអង្គﷺ ។ ព្រះអង្គﷺខិតបន្ដិចដើម្បីទុកកន្លែងឲ្យគាត់ ។ បុរសនោះសួរព្រះសាស្ដាﷺថាហេតុអ្វីព្រះអង្គﷺខិតចេញបន្ដិច ថ្វីបើសល់កន្លែងច្រើនសម្រាប់អង្គុយជិតព្រះអង្គﷺ ព្រោះពុំមានមនុស្សនៅក្នុងម៉ាស់យ៉ិដ្ឋទេ ។ ព្រះសាស្ដាﷺតបថាពេលមូស្លីមណាចង់អង្គុយជិតមូស្លីមម្នាក់ទៀត វាជាការសក្ដិសមណាស់ដែលមូស្លីមម្នាក់នោះខិតបន្ដិចជាការសម្ដែងសេចក្ដីគោរព ។

ថ្ងៃមុខថ្ងៃក្រោយ ពេលអ្នកនៅក្នុងម៉ាស់យ៉ិដ្ឋ អ្នកចាប់កន្លែងទុកឲ្យមិត្តអ្នក ចូរអ្នកចងចាំថាអ្នកត្រូវគេចចេញបើមានគេចង់អង្គុយកន្លែងដែលអ្នកចាប់ទុកនោះ ។

មនុស្សទាំងអស់ស្មើភាពគ្នា ។ ទោះបីអ្នកមានពណ៌សម្បុរអ្វីក៏ដោយ ទោះបីអ្នកមានជាតិសាសន៍អ្វីក៏ដោយ ទោះបីអ្នកមានក្ដីក្រក្ដី (ទោះបីអ្នកមានសំលៀកបំពាក់ស្អាតក្ដីមិនស្អាតក្ដី) ទោះបីអ្នកខុសពីគេក៏ដោយ (កាយវិកល) ។ មនុស្សទាំងអស់សុទ្ធតែមានសិទ្ធិទទួលបាននូវសេចក្ដីគោរព ។

ព្រះសាស្ដាﷺមានព្រះវចនៈថា៖ "ចូរកុំស្អប់ កុំមើលថោកមុស្លីមណាមួយឡើយ ពីព្រោះ ទោះបីមុស្លីមនោះគ្មានតម្លៃក៏ដោយ មុស្លីមនោះខ្ពង់ខ្ពស់សម្រាប់អល់ឡោះហ៊្វ عز وجل ។"

# លំហាត់ ៨

តើបុគ្គលមួយណា ក្នុងចំណោមបុគ្គលទាំងនេះ ប្រសើរជាងគេ ? ហេតុអ្វី ?



ចូរទន្ទេញអាយ៉ាត់ខាងក្រោមនេះឲ្យចាំ និងចូរសរសេរសម្រាយវានៅលើក្តារខៀន ។

يَـٰٓأَيُّهَا ٱلَّذِينَ ءَامَنُوا۟ لَا
يَسْخَرْ قَوْمٌ مِّن قَوْمٍ عَسَىٰٓ
أَن يَكُونُوا۟ خَيْرًا مِّنْهُمْ ﴿١١﴾



**មេរៀនទី ៨**

# ព្យាយាមមិនលះ

អល់ឡោះហ្ទ៏ﷻមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត្ទ៍ អាន់-ណាជ្ម៏ អាយ៉ាស់ ៣៩-៤១ ថា៖

وَأَن لَّيْسَ لِلْإِنسَٰنِ إِلَّا مَا سَعَىٰ ﴿٣٩﴾ وَأَنَّ سَعْيَهُۥ سَوْفَ يُرَىٰ ﴿٤٠﴾ ثُمَّ يُجْزَىٰهُ ٱلْجَزَآءَ ٱلْأَوْفَىٰ ﴿٤١﴾

*៣៩. មនុស្សនឹងមិនបានអ្វីក្រៅពី[លទ្ធផលនៃ]ការខំប្រឹងប្រែងរបស់ខ្លួនទេ (អំពើដែលខ្លួនបានសាង) ៤០. គេនឹងបង្ហាញការខំប្រឹងប្រែងរបស់អ្នកនោះឲ្យអ្នកនោះឃើញ ៤១. បន្ទាប់មក គេនឹងតបស្នងអ្នកនោះយ៉ាងពេញលេញដោយសារការខំប្រឹងប្រែងនេះ ។*(៥៣:៣៩-៤១)

អាយ៉ាស់ខាងលើនេះបញ្ជាក់ប្រាប់យើងថា យើងនឹងមិនបានសម្រេចទេបើយើងមិនព្យាយាម មិនខិតខំប្រឹងប្រែងទេនោះ ។

គន្លឹះនៃជោគជ័យគឺការខិតខំប្រឹងប្រែងមិនលះ ។ បើអ្នកមិនបានសម្រេចលើកដំបូងទេ ចូរព្យាយាមតទៅទៀតលុះបានជោគជ័យ ។ អ្នកមិនត្រូវលះបង់ជាដាច់ខាត ។

ប្រសិនបើអ្នកមិនបានសម្រេចដោយមូលហេតុណាមួយ ក្រោយពីបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាពក៏ដោយ ចូរអ្នកចងចាំថាអ្នកនឹងបានរង្វាន់ព្រោះតែអ្នកបានព្យាយាមអស់ពីសមត្ថភាពខ្លួន ដូចអល់ឡោះហ្ទ៏ﷻបានសន្យានៅក្នុងព្រះគម្ពីរគួរអាន នៅក្នុងអាយ៉ាស់ខាងលើនេះ ។

ព្រះចៅ អាមៀរ ទីមូរ ជាស្តេចម៉ុងកូលីមួយរូប ដែលល្បីថាជាបុគ្គលក្លាហាន ។ ស្តេចអង្គនេះបានវាយវាតយកទឹកដីបានពាក់កណ្តាលពិភពលោក ក្នុងសម័យនោះ ។ ព្រះចៅអង្គនេះបានថាជោគជ័យរបស់ព្រះអង្គនៅលើស្រមោចតូចមួយដែលបានបង្ហាត់បង្រៀនព្រះអង្គមិនឲ្យទម្លាក់ដៃលះបង់ចោលជាដាច់ខាត ។

កាលពីព្រះអង្គមិនទាន់បានទៅជាវិជ័យសង្គ្រាមដ៏ល្បីល្បាញ ព្រះអង្គបាន

ច្បាំង ហើយក៏ជិតចាញ់សង្គ្រាម ។ ព្រះអង្គបានសម្រេចចិត្តរត់គេចទៅពួនឯភ្នំ ។ នៅទីនោះ ព្រះអង្គអង្គុយដោយស្ងៀមស្ងាត់ ឃើញស្រមោចមួយកំពុងធ្វើការយ៉ាងសកម្ម ។ ស្រមោចតូចនេះលីគ្រប់អង្ករមួយដែលធំជាងខ្លួនវា ។ វាព្យាយាមឡើងលើជញ្ជាំងជាមួយគ្រាប់អង្ករ ។ គ្រាប់អង្ករធ្លាក់ វាចុះពីលើជញ្ជាំងទៅលីគ្រាប់អង្ករឡើងលើជញ្ជាំងវិញ ។ គ្រាប់អង្ករធ្លាក់ម្តងទៀត ស្រមោចក៏ចុះទៅរើសគ្រាប់អង្ករម្តងទៀត ។ ស្រមោចព្យាយាមម្តងហើយម្តងទៀតមិនលះបង់ចោលជាដាច់ខាត ។ ស្តេចបានរាប់ឃើញស្រមោចព្យាយាមធ្វើសាឡើងវិញ ៣៣ ដងមុននឹងអាចយកគ្រាប់អង្ករឡើងលើជញ្ជាំងបាននៅទីបំផុត ។



ពេលឃើញស្រមោចខិតខំប្រឹងប្រែងលុះបានសម្រេច ស្តេចអង្គនេះក៏បានប្រមែប្រមូលរេហ៍ពលទ័ពដែលបានរត់រប៉ាត់រប៉ាយ កឡើងជាកងទ័ពវិញ ។ ក្រោយពីបានឃើញការព្យាយាមរបស់ស្រមោចតូច ស្តេចមិនលះបង់ចោលសមរភូមិណាមួយឡើយ ហើយក៏បានទៅជាវិជ័យសង្គ្រាមដ៏ល្បីល្បាញ ។

ឧត្តមគតិរឿងនេះគឺ ដើម្បីបានសម្រេចកិច្ចការនានា អ្នកត្រូវព្យាយាមកុំលះលែង ។

# លំហាត់ ៨

តើស្តេចស្រង់បាននូវមេរៀនអ្វីពីស្រមោច ? ដូចម្តេច ?



ចូរបំពេញឃ្លានៅលើកូនសោខាងក្រោមនេះ ។




ប្រសិនបើអ្នកមិនបានសម្រេចដោយមូលហេតុណាមួយ ក្រោយពីបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាពក៏ដោយ តើអល់ឡោះហ្វ៊ូ عزّ وجلّ បានសន្យាអ្វី ?

## មេរៀនទី ៩

# ការច្រណែនឈ្នានីស

មានមនុស្ស ៣ ប្រភេទគឺ៖

១) មនុស្សភេទទី ១ មិនសូវអើពើអំពីការមានបានរបស់អ្នកដទៃទេ ។ ពួកគេអើពើតែដំណើរការជីវិតរបស់ខ្លួនប៉ុណ្ណោះ ។

២) មនុស្សប្រភេទទី ២ ពេលឃើញអ្នកដទៃមានបាន ខិតខំខ្លាំងឡើងដើម្បីមានបានដូចអ្នកដទៃដែរ ។

៣) មនុស្សប្រភេទទី ៣ មិនចូលចិត្តឃើញអ្នកផងមានបាននិងសុខសប្បាយទេ ។ មនុស្សប្រភេទនេះប៉ងឲ្យអ្នកដទៃវិនាសហិនហោច ។ គេហៅគំនិតនេះថាការច្រណែឈ្នានីស អល់ឡោះហ៍ﷻស្អប់អាកប្បកិរិយានេះ ។

តើអ្នកជាមនុស្សប្រភេទណា ? អល់ឡោះហ៍ﷻស្អប់ការច្រណែឈ្នានីសណាស់ ព្រះអង្គﷻមានព្រះបន្ទូលនៅក្នុងព្រះមហាគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាន់-នីសាអ៍ អាយ៉ាស់ ៥៤ ថា៖

أَمْ يَحْسُدُونَ ٱلنَّاسَ عَلَىٰ مَآ ءَاتَىٰهُمُ ٱللَّهُ مِن فَضْلِهِۦ ۖ ﴿٥٤﴾

*៥៤. ឬពួកគេច្រណែនឈ្នានីសនឹងជន ដោយសារតែអ្វីមួយដែលអល់ឡោះហ៍បានប្រទានឲ្យទៅនឹងជននោះក្នុងនាមនៃព្រះឧបការគុណព្រះអង្គ ?* (៤:៥៤)

អ្នកច្រណែនឈ្នានីសអ្នកដទៃ បានសេចក្តីថាអ្នកមិនពេញចិត្តទេដែលអល់ឡោះហ៍ﷻប្រទានអ្វីមួយឲ្យទៅអ្នកនោះ ។ ការពិតអ្នកចង់ប្រាប់អល់ឡោះហ៍ﷻថាព្រះអង្គﷻធ្វើខុស មិនស័ក្តិសមទេដែលព្រះអង្គﷻប្រទានអ្វីនោះឲ្យទៅអ្នកនោះ ។ ដូច្នេះអ្នកប្រកាសអះអាងថាអ្នកដឹងជាងអល់ឡោះហ៍ﷻ ។

ការច្រណែនឈ្នានីសធ្វើឲ្យខ្លួនអ្នកឈឺចាប់ជាងអ្វីៗទាំងអស់ ។ វាធ្វើឲ្យអ្នកមានទុក្ខ អរិជ្ជា ខ្វះការចេះដឹងនិងគិតតែប្រយោជន៍ឯង ។ គំរូប្រសើរបំផុតដែលបង្ហាញឲ្យឃើញថាការច្រណែនឈ្នានីសអាចធ្វើឲ្យខូចខាតនោះ គឺកូនរបស់ព្រះ

សាស្តាអាដាំﷺ កូប៊ីលនិងហាប៊ីល ។

ថ្ងៃមួយ ព្រះសាស្តាអាដាំﷺបានឲ្យកូប៊ីលនិងហាប៊ីលយកតង្វាយទៅថ្វាយអល់ឡោះហ៊្ស ។ អ្នកដែលអល់ឡោះហ៊្សព្រមទទួលយកតង្វាយនោះនឹងបានទៅជាអ្នកស្នងព្រះសាស្តាអាដាំﷺ ។ ហាប៊ីលដែលជាអ្នកចិញ្ចឹមសត្វបានយកសត្វល្អបង្អស់ទៅថ្វាយអល់ឡោះហ៊្ស ។ កូប៊ីលដែលជាកសិករបានយកកសិផលខូចទៅថ្វាយអល់ឡោះហ៊្ស ដោយគិតក្នុងចិត្តថាទោះបីយ៉ាងណាក៏ដោយ អល់ឡោះហ៊្សនឹងមិនសោយកសិផលទាំងនោះទេ ដូច្នេះមិនមានប្រយោជន៍ទេដែលយករបស់ល្អៗទៅថ្វាយអល់ឡោះហ៊្សនោះ ។ កូប៊ីលពុំបានគិតទេថាទោះបីអល់ឡោះហ៊្សមិនសោយមែនក៏ដោយ តែអល់ឡោះហ៊្សបានប្រាប់យើងថាពេលអ្នកឲ្យអ្វីមួយទៅអ្នកណាមួយ ចូរឲ្យអ្វីដែលល្អជាងគេដែលអ្នកមាន ។ ពិតណាស់ អល់ឡោះហ៊្សបានទទួលយកតង្វាយរបស់ហាប៊ីល ដែលបានឲ្យអ្វីដែលល្អជាងគេដែលខ្លួនមាន ។ រឿងនេះបានធ្វើឲ្យកូប៊ីលច្រណែនឈ្នានីសហាប៊ីលណាស់ ។ កូប៊ីលច្រណែនណាស់ដែលប្អូនខ្លួនទទួលតំណែងស្នងឪពុក ច្រណែនឈ្នានីសអត់មិនបានលុះសម្លាប់ប្អូនខ្លួនឯង ។ ក្រោយពីបានប្រព្រឹត្តអំពើនេះទើបកូប៊ីលចេះគិតហើយស្តាយក្រោយដោយស្មោះដែលបានធ្វើទង្វើនេះ តែហួសពេលស្រេច ។

អ្នកឃើញស្រាប់ហើយថា ការច្រណែនឈ្នានីសអាចធ្វើឲ្យយើងឆ្អែតចិត្តបាន វាមិនអាចផ្តល់ផលប្រយោជន៍ណាមួយឲ្យអ្នកបានទេ ។ ទោះបីកូប៊ីលបានសម្លាប់ប្អូនឯងក៏ដោយ ក៏ពុំអាចទៅអ្នកស្នងព្រះសាស្តាអាដាំﷺបានដែរ ។

អ៊ីមុាំអាលីصلوات الله عليه والسلامមានវចនៈថា៖ "ការច្រណែនឈ្នានីសធ្វើឲ្យទង្វើល្អវិនាស ដូចភ្លើងឆេះឈើស្ងួត ។"

## លំហាត់ ៩

ចូរសរសេរលើបន្ទះសំណេរខាងក្រោមនេះនូវប្រភេទមនុស្សទាំង ៣ ហើយចូរគូសលើក្រុមភេទមនុស្សដែលជាក្រុមរបស់អ្នក ។



ចូរទន្ទេញអាយ៉ាស់ខាងក្រោមនេះឲ្យចាំ និងចូរសរសេរសម្រាយវានៅលើក្ដារឆ្នួន ។

أَمْ يَحْسُدُونَ ٱلنَّاسَ عَلَىٰ مَآ
ءَاتَىٰهُمُ ٱللَّهُ مِن فَضْلِهِۦۖ ٥٤



## មេរៀនទី ១០

# មិត្តភាព

មនុស្សទាំងអស់ត្រូវការមិត្ត ។ តែមានតែមិត្តដែលស្មោះត្រង់ទេដែលមានតម្លៃ ។

ពនេជនពីរនាក់កំពុងធ្វើដំណើរជាមួយគ្នាតាមផ្លូវ ស្រាប់តែចោរបង្ហាញខ្លួនឆ្លោស្ទាក់ផ្លូវ ។ ម្នាក់រត់សំដៅដើមឈើ ឡើងទៅពួនលើនោះ ។ ម្នាក់ទៀតរត់មិនទាន់ក៏ដេកលើដីធ្វើពុតជាស្លាប់ ។ ចោរចូលមកជិតបុរសដេកនឹងដី ខ្សឹបដាក់ត្រចៀកបុរសនោះហើយក៏ចាកចេញទៅបាត់ ។ លុះចោរទៅផុត បុរសពួនលើដើមឈើចុះមកដីវិញ សួរមិត្តគាត់ថាតើចោរខ្សឹបអ្វីដាក់ត្រចៀកគាត់ ។ បុរសនោះក៏បានឆ្លើយប្រាប់មិត្តខ្លួនថាចោរបានប្រាប់ឲ្យគាត់រកមិត្តថ្មីដែលប្រសើរជាងមិត្តមុន ដែលមិនរត់ចោលមិត្តខ្លួនទេពេលឃើញសញ្ញាអាសន្នភ្លាមនោះ ។

មិត្តយកតម្រាប់តាមគ្នាវិស័យអាកប្បកិរិយា វិស័យគំនិតនិងវិស័យជំនឿ ។

ព្រះសាស្ដាﷺមានព្រះវចនៈថា៖ "អាកប្បកិរិយារបស់ម្នាក់ៗជាផលមកពីជំនឿនិងគោលសីលធម៌របស់មិត្រភក្ដិខ្លួន ។"

មនុស្សនឹងកាត់ថ្លៃអ្នកដោយផ្អែកទៅលើមិត្តអ្នក ទោះបីអ្នកគិតថាអ្នកជះឥទ្ធិពលល្អទៅលើមិត្តអ្នកក៏ដោយ ។

ព្រះសាស្ដាស៊ូឡៃម៉ានعَلَيْهِ السَّلَامមានព្រះវចនៈថា៖ "ចូរកុំសម្រេចជាមុនថាបុគ្គលណាមួយល្អឬអាក្រក់ ដរាបណាអ្នកមិនទាន់បានឃើញមិត្តភក្ដិបុគ្គលនោះ ពីព្រោះបុគ្គលនីមួយៗបង្ហាញមុខពិតអាស្រ័យលើការសេពគប់ គេស្គាល់បុគ្គលនោះអាស្រ័យមិត្តនិងក្លើម្រាក់របស់បុគ្គលនោះ ។"

អ៊ីមុាំយ៉ាក់ហ្វារ អាស្ស៊-ស្ឌិក្វصلوات الله عليه والسلامដើរក្នុងផ្សារជាមួយមិត្តព្រះអង្គصلوات الله عليه والسلامដែលអមដោយអ្នកបម្រើម្នាក់របស់គាត់ ។ មិត្តរបស់អ៊ីមុាំصلوات الله عليه والسلامបែរទៅនិយាយដាក់បម្រើ

គាត់ តែបម្រើគាត់នៅឆ្ងាយកំពុងតែនិយាយជាមួយគេ ។ បម្រើគាត់ក៏រត់មករកគាត់ មិត្តរបស់អ៊ីម៉ាំ صلوات الله عليه والسلام ក្រោធណាស់ គាត់ជេរដៀលត្មះបម្រើនោះ ថែមទាំងជេរដៀលត្មះម្តាយបម្រើនោះទៀតផង ។ បានឮសម្តីថ្លោសៗរបស់មិត្តព្រះអង្គ صلوات الله عليه والسلام អ៊ីម៉ាំ صلوات الله عليه والسلام ល្អក់ចិត្ត ប្រាប់មិត្តព្រះអង្គ صلوات الله عليه والسلام ថាគាត់មិនត្រូវដៀលត្មះបម្រើដូច្នេះទេ ជាពិសេសដៀលត្មះម្តាយគាត់ ។ មិត្តបានប្រាប់ព្រះអង្គ صلوات الله عليه والسلام ថាម្តាយរបស់បម្រើគាត់មិនមែនមុស្លីមទេ ។ អ៊ីម៉ាំ صلوات الله عليه والسلام បានឆ្លើយតបគាត់ថារឿងនេះមិនមានអ្វីខុសគ្នាទេ ។ ទីបំផុតអ៊ីម៉ាំ صلوات الله عليه والسلام បានប្រាប់មិត្តព្រះអង្គ صلوات الله عليه والسلام ថា មិត្តភាពរវាងព្រះអង្គ صلوات الله عليه والسلام និងមិត្តព្រះអង្គ صلوات الله عليه والسلام ត្រូវចប់ត្រឹមនេះ ហើយក៏បានដើរចេញពីមិត្តនោះ ។

អ៊ីម៉ាំទី ៤ របស់យើង គឺអ៊ីម៉ាំស្សែនុល-អាប៊ីឌីន صلوات الله عليه والسلام មានវចនៈថាអ្នកមិនត្រូវសេពគប់ជាមួយមនុស្ស ៥ ប្រភេទនេះទេ គឺ៖

១) មនុស្សនិយាយកុហក ពីព្រោះពេលនិយាយកុហកពួកគេធ្វើឲ្យអ្នកល្វៀងចេញពីផ្លូវល្អ ។

២) មនុស្សសាងបាប ពីព្រោះមិត្តភាពរបស់មនុស្សសាងបាបមិនគួរឲ្យទុកចិត្តទេ ។

៣) មនុស្សកំណាញ់ ពីព្រោះពេលទាល់ឬជួបប្រទះការលំបាក មនុស្សប្រភេទនេះនឹងរលាស់ដៃលែងជាមិត្តអ្នក ។

៤) មនុស្សឆ្កួត ពីព្រោះពួកគេអាចធ្វើអាក្រក់មកលើអ្នកដោយគិតថាខ្លួនធ្វើល្អចំពោះអ្នក ព្រោះតែពួកគេនេះមិនស្គាល់ខុសត្រូវ ។

៥) មនុស្សដែលផ្តាច់សម្ព័ន្ធពីគ្រួសារ ពីព្រោះមនុស្សប្រភេទនេះត្រូវអល់ឡោះហ៍ عز وجل ដាក់បណ្តាសា ។

ចូរកុំភ្លេចផងថាជួញមិត្តមិនគ្រប់គ្រាន់ទេ តែរក្សាមិត្តភាពនេះជាប្រការសំខាន់មួយដែរ ។ អាចធ្វើដូច្នេះបាន ទាល់តែយើងប្រព្រឹត្តចំពោះមិត្តយើងឲ្យដូចយើងចង់ឲ្យមិត្តយើងប្រព្រឹត្តចំពោះខ្លួនយើងដែរ ។

អ៊ីម៉ាំអាលី صلوات الله عليه والسلام មានវចនៈថា៖ "អ្នកណាគ្មានមិត្តអ្នកនោះអាប់ឱន តែអាប់ឱនលើសអ្នកនោះគឺបុគ្គលដែលមិនអាចរក្សាមិត្តភាពបាន ធ្វើឲ្យបាត់បង់មិត្តខ្លួន ។"

# លំហាត់ ១០

ចូរសរសេរនៅលើដៃខាងក្រោមនេះនូវមនុស្ស ៥ ប្រភេទដែលគេមិនត្រូវសេពគប់ជាមួយ ដោយយោលតាមសម្ដីអ៊ីម៉ាំអាលី ស្សៃនុល-អាប៊ីឌីន صلوات الله عليه والسلام ។



ចូរសរសេរនៅលើដៃនូវប្រការដែលអ្នកស្វែងរកពីមិត្តអ្នក ។



ចូរគូសលើដៃដែលអ្នកចង់ចាប់អង្រួននិងចង់សេពគប់ជាមិត្ត ។

**មេរៀនទី ១១**

# មានចំណេះ

ដើម្បីសហាគមន៍នឹងគង់វង្សនិងរីកចម្រើនទៅមុខក្នុងលោកនេះ សមាជិកសហាគមន៍ត្រូវមានចំណេះ ។

ស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចក្នុងសាសនាអ៊ីស្លាម ។

បាននូវចំណេះវិជ្ជា មិនត្រឹមតែទន្ទេញរត់មាត់ដូចសត្វសេកនោះទេ តែថែមទាំងយល់និងអនុវត្តិតាមចំណេះដែលទទួលបានមកនោះដែរ ហើយបង្ហាត់បង្រៀតអ្នកដទៃឲ្យចេះចំណេះនោះដើម្បីនឹងឲ្យពួកគេទទួលបាននូវផលប្រយោជន៍ផង ។

ព្រះសាស្តាﷺមានព្រះវចនៈថា មានចំណេះវិជ្ជាជាវ៉ាយិ៊បលើមុស្លីមប្រុសស្រី ។



ថ្ងៃមួយ ព្រះសាស្តាﷺបានចូលទៅក្នុងម៉ាស់យិ៊ដ្ឋ មានមនុស្សពីរក្រុមអង្គុយនៅក្នុងម៉ាស់យិ៊ដ្ឋនោះ ។ ក្រុមមួយកំពុងស្ម័ឡាត់ ក្រុមមួយទៀតកំពុងប្រឹក្សាគ្នារឿងសាសនា ។ ព្រះសាស្តាﷺរីករាយ ព្រះអង្គﷺមានវចនៈថាក្រុមទាំងពីរធ្វើប្រការល្អប្រសើរ តែព្រះអង្គﷺចូលចិត្តក្រុមដែលប្រឹក្សាគ្នា ។ ព្រះអង្គﷺក៏បានអង្គុយជាមួយក្រុមនេះ ។



សេចក្តីរាយការណ៍ខាងលើនេះ មិនមានន័យថាស្ម័ឡាត់មិនសំខាន់នោះទេ ព្រោះព្រះសាស្តាﷺស្រឡាញ់ទាំងពីរក្រុមនេះ ។ ក្រុមទីមួយស្ម័ឡាត់ស៊ូណាត់ មិនស្ម័ឡាត់វ៉ាយិ៊បទេ ។

ចំណេះចេះដឹងដែលយើងត្រូវមានពាក់ព័ន្ធវិស័យទាំងអស់ ទាំងវិស័យ

សាសនា ទាំងវិស័យសិក្សា ។ គេអាចស្ទាត់ជំនាញទាំងពីរវិស័យបាន ។ ព្រោះតែអល់ឡោះហ្វ៍ﷻបង្កើតយើង ព្រះអង្គﷻដឹងថាយើងមានសមត្ថភាពធ្វើអ្វីបាន ។ បើអ្នកចេះដឹងវិស័យសាសនាកើនឡើង អ្នកនឹងកាន់តែនៅជិតអល់ឡោះហ្វ៍ﷻព្រោះអ្នកនឹងយល់ច្បាស់ជាងមុនថាអ្នកធ្វើអ្វីនិងហេតុអ្វី ។

បើពីរនាក់ប្រតិបត្តិស្វ៊ឡាត្ទុំតែមួយ ម្នាក់យល់ស្វ៊ឡាត្ទុំនោះ ម្នាក់ទៀតមិនយល់ស្វ៊ឡាត្ទុំនោះទេ យើងដឹងថាអ្នកដែលយល់ស្វ៊ឡាត្ទុំនោះនឹងបានរង្វាន់ច្រើនជាងអ្នកដែលមិនយល់ស្វ៊ឡាត្ទុំនោះ ។

សាសនាអ៊ីស្លាមជាសាសនាមួយគត់ដែលសូមឲ្យអ្នកសួរ និងឲ្យស៊ើបសួរអំពីអ្វីៗទាំងអស់ ទាំងអំពីសាសនាអ៊ីស្លាមផងដែរ មិនឲ្យអនុវត្តតាមទាំងបិទភ្នែកទេ ។

ថ្ងៃគីយ៉ាម៉ាត្ទុំ ពេលគេសួរអ្នកអំពីទង្វើអាក្រក់ដែលអ្នកបានធ្វើ អ្នកមិនអាចឆ្លើយថាអ្នកមិនដឹងបានទេ! អ្នកពុំអាចដោះសាបានទេ ។ មានសៀវភៅច្រើនណាស់ដែលអ្នកអាចអានបាន មានមនុស្សច្រើនណាស់ដែលអ្នកអាចសួរបាន ។

ដូច្នេះ ពេលអ្នកដឹងមិនប្រាកដឬមិនច្បាស់អំពីអ្វីមួយ ជាពិសេសអំពីវ៉ាយិ៊ប ចូរអ្នកសាកសួរពីពេលឥឡូវនេះ ពីព្រោះអ្នកអាចមិនរស់រានបានដល់ទៅថ្ងៃស្អែក ។

## លំហាត់ ១១

ចូរសរសេរនៅលើសន្លឹកក្រដាសថាហេតុអ្វីត្រូវមានចំណេះចេះដឹង ។



## មេរៀនទី ១២

# ការអត់ធ្មត់ (صَبَر)

អល់ឡោះហ៊្វ ﷻ មានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៊្វ អាល់-បាក៏រ៉ោះត៊្វ អាយ៉ាស៊្វ ១៥៣ ថា៖

إِنَّ ٱللَّهَ مَعَ ٱلصَّٰبِرِينَ ﴿١٥٣﴾

*១៥៣. ... ពិតណាស់អល់ឡោះហ៊្វនៅខាងអ្នកអត់ធ្មត់។* (២:១៥៣)

អាយ៉ាស៊្វខាងលើនេះថែងប្រាប់យើងថាបើយើងមានអំណត់ (ស៊្វបារ) អល់ឡោះហ៊្វ ﷻ នឹងមិនចោលយើងទេ ។ យើងដឹងហើយថាបើអល់ឡោះហ៊្វ ﷻ នៅខាងយើង យើងនឹងមិនបារម្ភទេ ។

ព្រះសាស្តា ﷺ មានព្រះវចនៈថាត្រូវមានអំណត់ ៣ ពេលគឺ៖

១) មានអំណត់ (ស៊្វបារ) ពេលលំបាក គឺពេលអ្នកមានបញ្ហា ។

២) មានអំណត់និងស្តាប់បង្គាប់ ។ អនុវត្តិកាតព្វកិច្ច (វ៉ាយ៊ីបាត់) ទាំងអស់យ៉ាងត្រឹមត្រូវ ។

៣) មានអំណត់និងមិនល្មើស ។ មិនប្រព្រឹត្តអំពើដែលច្បាប់ហាម (គឺអំពើហ្ារ៉ាំ) ។

អំណត់គំរូដែលល្អបំផុត គឺការអត់ធ្មត់របស់ព្រះសាស្តាអៃយ៉ូប عليه السلام មួយជីវិតព្រះអង្គ عليه السلام ។ អល់ឡោះហ៊្វ ﷻ បានប្រោសប្រទានសព្វគ្រប់ឲ្យព្រះអង្គ عليه السلام (សុខភាព កូន ទ្រព្យសម្បត្តិ ដីធ្លីនិងសត្វ) ។ ស្ហៃតន لعنه الله បានសូមឲ្យអល់ឡោះហ៊្វ ﷻ ឲ្យវា لعنه الله មានអំណាចលើរឿងផ្ទាល់ខ្លួនរបស់ព្រះសាស្តាអៃយ៉ូប عليه السلام ដោយអះអាងថាដរាបណាព្រះសាស្តាអៃយ៉ូប عليه السلام មានបាន ដរាបនោះព្រះអង្គ عليه السلام នៅតែអរព្រះគុណអល់ឡោះហ៊្វ ﷻ តែបើគេដកហូតយកអ្វីទាំងអស់ពីព្រះអង្គ عليه السلام ធ្វើឲ្យព្រះអង្គ عليه السلام អស់ខ្លួន ព្រះអង្គ عليه السلام នឹងល្មៀងចេញពីអល់ឡោះហ៊្វ ﷻ ។ ស្ហៃតន لعنه الله ក៏បានកម្ទេចសត្វនិងទ្រព្យទាំងអស់របស់ព្រះសាស្តាអៃយ៉ូប عليه السلام ។ អាក្រក់លើសនោះ វា لعنه الله បាន

សម្លាប់កូនទាំងអស់របស់ព្រះអង្គعليه السلامដែរ ។ បន្ទាប់មកវាلعنه اللهបានធ្វើឲ្យព្រះអង្គعليه السلام រងជម្ងឺអាក្រក់ ប្រជារាស្ត្រព្រះអង្គعليه السلامបានបង្ខំព្រះអង្គعليه السلامឲ្យចាកចេញពីក្នុងស្រុក ។

ទោះបីព្រះសាស្តាអៃយ៉ូបعليه السلامរងទុក្ខវេទនាទាំងនេះក៏ដោយ ព្រះអង្គعليه السلامនៅតែស្ម័គ្រស្មោះចំពោះអល់ឡោះហ៊្ហ៍عز وجلជានិច្ច នៅតែបួងសួងអល់ឡោះហ៊្ហ៍عز وجل នៅតែអរព្រះគុណអល់ឡោះហ៊្ហ៍عز وجلចំពោះអ្វីៗទាំងអស់ ។ ព្រះអង្គعليه السلامមិនត្រឹមតែមានអំណត់ (ស្ប៏បារ) មួយមុខទេ តែព្រះអង្គعليه السلامដឹងព្រះគុណទៀតផង ។

ព្រះសាស្តាصلى الله عليه وآله وسلمមានព្រះវចនៈថាជំនឿបែងចែកជា ២ គឺៈ ពាក់កណ្តាលជាអំណត់ (ស្ប៏បារ) ពាក់កណ្តាលទៀតជាកតញ្ញូតា (ការដឹងគុណ) ។

ហាឌីស្ហខាងលើនេះបញ្ជាក់ប្រាប់យើងថា ដើម្បីមានជំនឿពិតប្រាកដចំពោះសាសនាអ៊ីស្លាម យើងមិនត្រឹមតែមានអំណត់តែម្យ៉ាងទេ តែយើងត្រូវមានកតញ្ញូតាផង (គឺត្រូវដឹងព្រះគុណអល់ឡោះហ៊្ហ៍عز وجلផង) ។ ដូច្នេះ អំណឹះតទៅ ពេលអ្នកមានវិបត្តិ អ្នកមិនត្រឹមតែត្រូវមានការអត់ធ្មត់តែម្យ៉ាងទេ តែអ្នកត្រូវអរព្រះគុណអល់ឡោះហ៊្ហ៍عز وجلផង ព្រោះអល់ឡោះហ៊្ហ៍عز وجلដឹងជាងគេ ។

ថ្ងៃមួយ មនុស្សមួយក្រុមបានមករកអ៊ីម៉ាំទី ៤ របស់យើង គឺអ៊ីម៉ាំ អាលី ស្សៃនុល-អាប៊ីឌីនصلوات الله عليه والسلام ប្រាប់ព្រះអង្គصلوات الله عليه والسلامថាពួកគេជាស្ហ៊ីអាស្ហ់របស់ព្រះអង្គعليه السلام ។ អ៊ីម៉ាំصلوات الله عليه والسلامបានសួរពួកគាត់ថា តើពួកគាត់ធ្វើអ្វីពេលអ្វីមួយដែលល្អប្រពៃកើតមានដល់ពួកគាត់ ។ ពួកគាត់បានតបថាពួកគាត់ថា "អាល់-ហាំឌុ លិលឡាស្ហ់" ។ អ៊ីម៉ាំصلوات الله عليه والسلامបានសួរពួកគាត់ថា តើពួកគាត់ធ្វើអ្វីពេលអ្វីមួយដែលល្អប្រពៃត្រូវដកហូតពីពួកគាត់ ។ ពួកគាត់បានតបថាពួកគាត់នឹងក្រោធមួយភ្លែត ហើយពួកគាត់នឹងលៃលកតាមនោះ ។ អ៊ីម៉ាំصلوات الله عليه والسلامបានសួរពួកគាត់ថាតើពួកគាត់ធ្វើអ្វីបើពួកគាត់មិនបានទទួលអ្វីសោះ ។ ពួកគាត់បានតបថាពួកគាត់នឹងមិនធ្វើអ្វីឡើយ ។ អ៊ីម៉ាំصلوات الله عليه والسلامបានឆ្លើយពួកគាត់ថាស្ហ៊ីអាស្ហ់ព្រះអង្គصلوات الله عليه والسلامមិនគប្បីធ្វើទង្វើទាំងនេះទេ ។ ទង្វើទាំងនេះដូចទង្វើរបស់សត្វឆ្កែនៅម៉ាឌីណាស្ហ់ ។ បើគេឲ្យអ្វីទៅឆ្កែ វានឹងបក់កន្ទុយសម្តែងនូវការដឹងគុណ ។ បើគេយកអ្វីពីឆ្កែ វានឹងព្រុសមួយស្របក់ (តវ៉ា) រួចហើយក៏ដើរចេញ ។ បើវាមិនបានអ្វីទេ វាមិនធ្វើអ្វីទេ ។ អ៊ីម៉ាំصلوات الله عليه والسلامមានវចនៈបន្តថាស្ហ៊ីអាស្ហ់គឺ

បណ្តាអ្នកដែលថា "អាល់-ហ្ញាំឌូ លិលឡាស្ញ" ពេលទទួលបានអ្វីមួយ ថា "អាល់-ហ្ញាំឌូ លិលឡាស្ញ" ពេលគេដកហូតអ្វីមួយពីពួកគេ ថា "អាល់-ហ្ញាំឌូ លិលឡាស្ញ" ពេលពួកគេមិនទទួលបានអ្វីទេ ។

## លំហាត់ ១២

អល់ឡោះហ្ទ៏ﷻប្រោសប្រទានឲ្យព្រះសាស្ដាអៃយ៉ូបعليه السلامច្រើនណាស់ ។ ព្រះអង្គعليه السلامជាអ្នកមាន សម្បូរសត្វ សម្បូរដីធ្លី ។ ព្រះអង្គعليه السلامមានកូនច្រើន មនុស្សគោរពព្រះអង្គعليه السلام ។




តើអ្វីកើតឡើងចំពោះព្រះអំណោយទាំងនេះ ? ហេតុអ្វី ?

______________________________________________

______________________________________________

តើព្រះសាស្ដាអៃយ៉ូបعليه السلامធ្វើអ្វីពេលព្រះអង្គعليه السلامរងគ្រោះទាំងនេះ ?

______________________________________________

______________________________________________

## មេរៀនទី ១៣

# ចូរអនុវត្តអ្វីដែលអ្នកថា

អល់ឡោះហ៍ﷻមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ អាយ៉ាស់ ៤៤ ថា៖

۞أَتَأۡمُرُونَ ٱلنَّاسَ بِٱلۡبِرِّ وَتَنسَوۡنَ أَنفُسَكُمۡ ﴿٤٤﴾

*៤៤. ពួកអ្នកបញ្ជាឲ្យបណ្តាមនុស្សធ្វើល្អ[និងជឿស៊ប់ចិត្ត] ឯខ្លួនពួកអ្នកផ្ទាល់មិនយកចិត្តទុកដាក់[ធ្វើល្អនិងជឿស៊ប់ចិត្ត]ទេ...* (២:៤៤) ។

អាយ៉ាស់ខាងលើនេះព្រមានយើងអំពីការប្រាប់អ្នកដទៃឲ្យធ្វើល្អ ឯខ្លួនឯងវិញមិនធ្វើទេ ។ មនុស្សនឹងមិនស្តាប់អ្នកទេបើអ្នកប្រាប់ឲ្យគេធ្វើអ្វីមួយតែខ្លួនអ្នកផ្ទាល់មិនធ្វើដែរទេនោះ ។ ការពិតអ្នកមិនមានសិទ្ធិប្រាប់គេឲ្យធ្វើឬមិនឲ្យធ្វើអ្វីមួយទេ លើកលែងតែខ្លួនអ្នកផ្ទាល់ធ្វើអ្វីដែលអ្នកថា ។

ចូរស្មានមើលចុះថា ព្រះសាស្តាយើងعليهم السلامឬអ៊ីម៉ាំយើងعليهم السلامបានបង្ហាត់បង្រៀនយើងឲ្យចេះដឹងសាសនាអ៊ីស្លាមនិងអ្វីដែលអល់ឡោះហ៍ﷻចង់ឲ្យយើងធ្វើ ឬអ្វីដែលព្រះអង្គﷻមិនចង់ឲ្យយើងធ្វើ តែខ្លួនព្រះអង្គផ្ទាល់عليهم السلامមិនអនុវត្តអ្វីដែលព្រះអង្គعليهم السلامថាទេ តើមានអ្នកណាមួយស្តាប់ឬតាមព្រះអង្គعليهم السلامទេ ? ទេ ! ច្បាស់ជាពុំមានគេតាមឬពុំមានគេស្តាប់ព្រះអង្គعليهم السلامទេ ។

មធ្យោបាយប្រសើរបំផុតសម្រាប់ឲ្យគេធ្វើល្អនិងធ្វើអាក្រក់នោះ ជាចម្បងគឺអាស្រ័យលើទង្វើអ្នក បន្ទាប់មកគឺអាស្រ័យលើសម្តីអ្នក ។

ហេតុដូច្នេះឯង បានជាព្រះសាស្តាﷺយើងបានរស់នៅក្នុងចំណោមមនុស្សអស់រយៈពេល ៤០ ឆ្នាំ ដើម្បីឲ្យមនុស្សឃើញថាត្រូវធ្វើបែបណា មិនត្រូវធ្វើបែបណា មុនព្រះអង្គﷺបើកឲ្យដឹងថាព្រះអង្គﷺជាព្រះសាស្តារបស់អល់ឡោះហ៍ﷻ ។

ថ្ងៃមួយ បុរសអាលិមម្នាក់បានថ្លែងនៅក្នុងអង្គប្រជុំថា "ប៊ិសមិលឡាស់" មានឥទ្ធិពលខ្លាំងណាស់ បើអ្នកណាជឿ "ប៊ិសមិលឡាស់" នេះដោយស្មោះ អ្នកនោះនឹងអាចដើរលើទឹកបាន ។

យប់ថ្ងៃនោះ បុរសម្នាក់ត្រឡប់ទៅផ្ទះវិញ (ដែលនៅត្រើយម្ខាងស្ទឹង) ។ គាត់សម្រេចចិត្តសាកល្បងអនុវត្តិសម្ដីរបស់បុរសអាលិម ។ ដូច្នេះ ដោយជឿជាក់ចំពោះអំណាចរបស់អល់ឡោះហ្ម៉ ﷻ គាត់ថា "ប៊ិសមិលឡាស្ស៉" ហើយក៏ឈានជើងទៅរកទឹក ។ គាត់ក៏អាចដើរលើទឹកបានដោយសារគាត់ជឿអល់ឡោះហ្ម៉ ﷻ ។

ថ្ងៃបន្ទាប់ បុរសនេះបានទៅរកបុរសអាលិម អញ្ជើញលោកមកទទួលទានបាយឯផ្ទះគាត់ដើម្បីអរគុណលោក ដែលបានបង្ហាត់បង្រៀនគាត់ឲ្យចេះដឹងឥទ្ធិពលរបស់ "ប៊ិសមិលឡាស្ស៉" ។ បុរសអាលិមទទួលការសូមអញ្ជើញ ។

ទាំងពីរនាក់ក៏បានចេញដំណើរទៅឯផ្ទះបុរស ។ នៅមាត់ស្ទឹង បុរសនោះបានថា "ប៊ិសមិលឡាស្ស៉" ហើយក៏ដើរលើទឹកដោយគិតថាបុរសអាលិមធ្វើដូចគាត់ដែរព្រោះលោកជាអ្នកបង្ហាត់គាត់ឲ្យចេះដើរលើទឹក ។ តែបុរសអាលិមឈរឯមាត់ទឹកមិនហ៊ានដើរលើទឹកទេ ។ លោកមិនជឿពិតប្រាកដឥទ្ធិពលដែលគាត់បង្ហាត់គេយ៉ាងញឹកញយនោះទេ ។ លោកមិនអនុវត្តអ្វីដែលលោកប្រាប់គេឲ្យធ្វើនោះទេ ។

ដូច្នេះ មុននឹងប្រាប់មិត្តអ្នកឬប្អូនប្រុសស្រីរបស់អ្នកនូវអ្វីដែលត្រូវធ្វើឬមិនត្រូវធ្វើនោះ ចូរអ្នកសួរខ្លួនឯងថាតើអ្នកបានអនុវត្តិខ្លួនឯងហើយឬនៅ ?

# លំហាត់ ១៣

តើបុរសអ៊ុលិមបង្រៀនអ្វីឲ្យបុរសម្នាក់នោះ អំពីឥទ្ធិពលរបស់ بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ *(ខ្ញុំចាប់ផ្តើម)ដោយនូវព្រះនាមអល់ឡោះប៉ុ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី)* ?



តើអ្វីកើតឡើងពេលបុរសបានឈានជើងទៅរកទឹក បន្ទាប់ពីបានថា "ប៊ិសមិលឡាស៊ុ" ?

_______________________________________________

_______________________________________________

ហេតុអ្វីបុរសអ៊ុលិមមិនអាចដើរឆ្លងទឹកបានតាមបុរស ?

_______________________________________________

_______________________________________________

ចូរនិយាយតំណាលកាលអ្នកប្រាប់គេឲ្យធ្វើតែខ្លួនអ្នកមិនធ្វើទេ (អ្នកមិនអនុវត្តអ្វីដែលអ្នកថាទេ) ។

_______________________________________________

_______________________________________________

**មេរៀនទី ១៤**

# គោរពពាក្យសន្យា

អល់ឡោះហ្ជ៏ جل មានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ បានី អ៊ីសរ៉អ៊ីល អាយ៉ាត់ ៣៤ ថា៖

وَأَوْفُوا۟ بِٱلْعَهْدِ ۖ إِنَّ ٱلْعَهْدَ كَانَ مَسْـُٔولًا ﴿٣٤﴾

*៣៤. ... ចូរពួកអ្នកគោរពពាក្យសន្យា ព្រោះគេនឹងសាកសួរអំពីពាក្យសន្យានេះ ។* (១៧:៣៤)

អាយ៉ាត់នេះបញ្ជាក់ប្រាប់យើងថា បើយើងសន្យាអ្វីមួយចំពោះអ្នកណាមួយ យើងត្រូវតែធ្វើតាមពាក្យសន្យានោះ ព្រោះយើងនឹងត្រូវសាកសួរអំពីពាក្យសន្យានេះក្នុងថ្ងៃជំនុំជម្រះ ។

អ៊ីម៉ាំទី ១ របស់យើង គឺអ៊ីម៉ាំអាលី صلوات الله عليه والسلام មានវចនៈថាយើងមិនត្រូវសន្យាទេតាំងពីដើម បើយើងមិនអាចគោរពពាក្យសន្យានោះបានទេ យើងមិនត្រូវសន្យាធ្វើអ្វីដែលយើងមិនអាចគ្រប់គ្រងបាននោះទេ ។ ព្រះអង្គ صلوات الله عليه والسلام បន្ថែមថាយើងមិនត្រូវសន្យាទេពេលយើងមិនជឿជាក់ថាងាយធ្វើតាមសន្យានោះបាន ហើយមិនជាក់ថាអាចគោរពពាក្យសន្យានោះបានទេ ។

ហាឌីស្ហនេះបញ្ជាក់ថាយើងត្រូវគិតសិនមុននឹងសន្យាអ្វីមួយ ថាយើងអាចគោរពពាក្យសន្យានោះបានឬទេ ? បើគោរពពាក្យសន្យាមិនបានទេ ចូរកុំសន្យា ពុំមានបាបទេបើយើងមិនសន្យាឲ្យគេទេនោះ តែនឹងមានបាបបើយើងក្បត់ពាក្យសន្យាក្រោយពីបានសន្យាហើយ ។

ថ្ងៃមួយ មុស្លីមម្នាក់ជាប់ពន្ធនាគារ ជាប់ចោទថាបានវាយមុស្លីមម្នាក់ទៀត និងជាប់ចោទថាបានបះបោរប្រឆាំងរាជរដ្ឋាភិបាល ។ គាត់សូមឲ្យនគរបាលអនុញ្ញាតឲ្យគាត់ទៅជួបគ្រួសារគាត់ដោយសន្យាថាគាត់នឹងត្រឡប់មកវិញ ព្រោះគ្រួសារគាត់មិនដឹងដំណឹងគាត់ទេ ។ បុរសនេះបានថាគាត់មិនបានវាយគេទេ មិន

បានបះបោរប្រឆាំងរាជរដ្ឋាភិបាលទេ ថាគាត់មិនបានធ្វើខុសច្បាប់ទេ ថាគេចោទគាត់ដោយគ្មានហេតុផល តែព្រោះតែគាត់ជឿថាអល់ឡោះហ្ជ ﷻ មានធម៌សន្តោស គាត់នឹងមិនរត់ទេ គាត់បានសន្យាថានឹងត្រឡប់មកវិញព្រឹកថ្ងៃស្អែក ។ សម្ដីបុរសនេះធ្វើឲ្យភ្នាក់ងារនគរបាលរំភើបចិត្តណាស់ ភ្នាក់ងារនគរបាលនេះក៏បានយល់ព្រម ។

លុះបុរសជាប់ចោទចេញទៅផុតទើបភ្នាក់ងារនគរបាលភ្ញាក់ខ្លួនវិញ ស្ដាយក្រោយ ។ តើគាត់នឹងប្រាប់ស្ដេចថាអ្វី ? ភ្នាក់ងារនគរបាលខ្វល់ខ្វាយដេកមិនលក់ ដើរទៅដើរមកដូចស្ការជាប់ទ្រុង សួរខ្លួនឯងថាតើនឹងនិយាយអ្វីប្រាប់ស្ដេចថាគាត់បានដោះលែងបុរសជាប់ចោទ ។

ព្រឹកឡើង បុរសជាប់ចោទបានគោរពពាក្យសន្យា គាត់ត្រឡប់មកវិញ ។ ភ្នាក់ងារនគរបាលឆ្ងល់ពេកក៏សួរគាត់ថាហេតុអ្វីត្រឡប់មកវិញ មិនយកឱកាសនេះរត់គេចខ្លួន ។ បុរសជាប់ចោទបានតបថាគាត់បានសន្យាហើយថានឹងត្រឡប់មកវិញ ថាគាត់មិនអាចក្បត់ពាក្យសន្យានេះបានទេ ព្រោះគាត់នឹងចាំបាច់ត្រូវឆ្លើយអល់ឡោះហ្ជ ﷻ អំពីរឿងនេះ ។

ពេលគេប្រាប់ស្ដេចឲ្យដឹងព្រឹត្តិការណ៍ ដែលបានកើតឡើងកាលពីយប់មិញ ស្ដេចក៏បានយល់ថា មនុស្សដែលមានជំនឿស៊ប់ចិត្តលើអល់ឡោះហ្ជ ﷻ ថ្នាក់នេះមិនអាចប្រព្រឹត្តបទឧក្រិដ្ឋដែលគេចោទគាត់នោះបានទេ ។ ស្ដេចក៏បានដោះលែងបុរសនេះឲ្យមានសេរីភាពវិញ ។

ចូរអ្នកចងចាំជានិច្ចថាគោរពពាក្យសន្យាជាវ៉ាយិប ទោះបីពាក្យសន្យានោះតូចក៏ដោយ ធំក៏ដោយ ទោះបីសន្យាជាមួយមុស្លីមក៏ដោយ ទោះបីសន្យាជាមួយមនុស្សមិនមែនមុស្លីមក៏ដោយ ។

ដូច្នេះ ចូរគិតសិនមុនសន្យា ។

# លំហាត់ ១៤



ហេតុអ្វីភ្នាក់ងារនគរបាលដោះលែងបុរសជាប់ចោទ ?

______________________________

______________________________

តើបុរសជាប់ចោតគោរពពាក្យសន្យាទេ ? ហេតុអ្វី ?

______________________________

______________________________

ហេតុអ្វីស្ដេចដោះលែងបុរសជាប់ចោទឲ្យមានសេរីភាពវិញ ?

______________________________

______________________________

អ្វីដែលវ៉ាឃ្លិប សន្យាឲ្យគេ ឬ គោរពពាក្យសន្យា ?

______________________________

______________________________

តើអ្នកត្រូវគិតអ្វីខ្លះមុននឹងសន្យា ?

______________________________

______________________________

**មេរៀនទី ១៥**

# ប្រកាន់ខ្លួន

អល់ឡោះហ្ទ៍﷿មានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះតុ៍ អាល់-បាក៏រ៉ោះតុ៍ អាយ៉ាស់ ៣៤ ថា៖

وَإِذْ قُلْنَا لِلْمَلَٰٓئِكَةِ ٱسْجُدُوا۟ لِءَادَمَ فَسَجَدُوٓا۟ إِلَّآ إِبْلِيسَ أَبَىٰ وَٱسْتَكْبَرَ وَكَانَ مِنَ ٱلْكَٰفِرِينَ ﴿٣٤﴾

*៣៤. កាលយើងបានត្រាស់ទៅអស់ទេវតាថា៖ "ពួកអ្នកចូរក្រាបប្រណិប័តន៍អាដាំ ។" ពួកគេបានក្រាបប្រណិប័តន៍ លើកលែងតែអ៊ីបលីសដែលជំទាស់ដោយក្រអឺតងងើល ហើយគេជាម្នាក់ក្នុងចំណោមពួកបដិសេធសទ្ធា ។*(២:៣៤)

អ៊ីប្លីសជាយ៉ិនដែលអល់ឡោះហ្ទ៍﷿បានលើកឡើងទៅលើមេឃ ព្រោះវាជាយ៉ិនល្អបំផុត ។ តែពេលអល់ឡោះហ្ទ៍﷿បង្កើតអាដាំعليه السلام ព្រះអង្គ﷿បានឲ្យអ៊ីប្លីសក្រាបប្រណិប័តន៍ (សាច់ដ្ញាស់) អាដាំعليه السلام អ៊ីប្លីសបានបដិសេធដោយប្រកែកតវ៉ាថាវាប្រសើរជាងអាដាំعليه السلامព្រោះវាត្រូវបង្កើតមកពីភ្លើង ចំណែកឯអាដាំعليه السلامវិញត្រូវបង្កើតមកពីដី ។ អ៊ីប្លីសបានល្មើសព្រះបញ្ជាអល់ឡោះហ្ទ៍﷿ដោយសារតែវាប្រកាន់ខ្លួន (ក្រអឺតក្រអោង) ហេតុដូចច្នេះឯងបានជាវាត្រូវបណ្តេញចេញពីឋានសួគ៌ ហើយនឹងត្រូវចូលឋាននរក ត្រូវដុតកម្លោចនៅក្នុងឋាននរកនោះរហូត ។

អ្វីទៅការប្រកាន់ខ្លួន ? ការប្រកាន់ខ្លួនធ្វើឲ្យបុគ្គលជឿថាខ្លួនឯងប្រសើរជាងអ្នកដទៃ ។ អ្នកដែលជឿថាខ្លួនឯងប្រសើរជាងគេគិតថាអ្នកដទៃអន់ជាងខ្លួន ។ អ្នកនោះភ្លេចកំហុសខ្លួនឯង មិននឹកដល់ព្រះគុណអល់ឡោះហ្ទ៍﷿ទេ ។

ដើម្បីកម្ចាត់ការប្រកាន់ខ្លួន អ្នកត្រូវគិតដល់អល់ឡោះហ្ទ៍﷿ ត្រូវដឹងថាមានតែព្រះអង្គ﷿មួយគត់ជាអ្នកបង្កើត ជាអ្នកខ្លាំងពូកែកំពូល ដែលស័ក្តិសមឲ្យគេស្ញើចសរសើរនិងគោរពបូជា ។

ព្រះសាស្តាﷺយើងមានព្រះវចនៈថា អល់ឡោះហ្ទ៍﷿មានព្រះបន្ទូលថា៖

"ភាពថ្កើងថ្កានជាសិទ្ធិរបស់អញﷻមួយគត់ អ្នកណាប៉ងចូលរួមចំណែកសិទ្ធិនេះជាមួយអញﷻ (ដោយមានមោទនភាពជ្រុលពេក) អញﷻនឹងដាក់អ្នកនោះទៅក្នុងឋាននរក ។"

ប្រសិនបើអ្នកមានអារម្មណ៍ថាអ្នកលើកខ្លួនឯងជ្រុលពេក ចូរអ្នកគិតដល់ពេលដែលអ្នកកើតមក កាលអ្នកទើបនឹងចេញពីក្នុងពោះម្ដាយ (ជាទារកគ្មានសមត្ថភាពធ្វើអ្វីបានដោយខ្លួនឯងឡើយ) បន្ទាប់មកចូរគិតដល់អវសានរបស់អ្នក (នៅក្នុងផ្នូរ) ។

បើប្រៀបធៀបនឹងអល់ឡោះហ្ទ៍ﷻ យើងអសារៈ (មិនសំខាន់សោះ) ។ យើងពុំមានហេតុផលប្រកាន់ខ្លួនខ្ពស់ត្រដែតសោះឡើយ ។ មានតែអល់ឡោះហ្ទ៍ﷻទេដែលមានសិទ្ធិលើកតម្កើងខ្លួនឯង ។

# លំហាត់ ១៥

ចូរបង្គ្រប់ពាក្យក្នុងឃ្លាខាងក្រោមនេះ ។

**ការលើកតម្កើងខ្លួនឯងជាកម្មសិទ្ធិរបស់ _ _ _ _ មួយគត់ ។**

ចូរអ្នកអធិប្បាយបំភ្លឺថាហេតុអ្វីអ្នកយល់ឃើញថាឃ្លាខាងលើនេះត្រឹមត្រូវ ។

______________________________________________

______________________________________________

## មេរៀនទី ១៦

# សូមខមាទោស (اَلتَّوْبَة)

អល់ឡោះហ្ទ៏ﷻមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាស្ស-ស៊្ហូម៉ារ អាយ៉ាស់ ៥៣ ថា៖

لَا تَقْنَطُوا۟ مِن رَّحْمَةِ ٱللَّهِ ۚ إِنَّ ٱللَّهَ يَغْفِرُ ٱلذُّنُوبَ جَمِيعًا ۚ إِنَّهُۥ هُوَ ٱلْغَفُورُ ٱلرَّحِيمُ ﴿٥٣﴾

*៥៣. ចូរកុំអស់សង្ឃឹមនឹងបានទទួលព្រះមេត្តាធម៌របស់អល់ឡោះហ្ទ៏ឡើយ ។ ការពិតអល់ឡោះហ្ទ៏ទ្រង់លើកលែងកំហុសទាំងអស់ ។ ការពិតព្រះអង្គគឺព្រះដែលអភ័យទោស ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។* (៣៩:៥៣)

អាយ៉ាស់នេះបញ្ជាក់ប្រាប់យើងថាកុំឲ្យអស់សង្ឃឹម កុំឲ្យអស់សេចក្តីប្រាថ្នាជាដាច់ខាត ពីព្រោះអល់ឡោះហ្ទ៏ﷻនឹងលើកលែងទោសឲ្យយើងព្រោះព្រះអង្គﷻមានព្រះមេត្តាធម៌ មានព្រះករុណាប្រណីបំផុត ។

មិនបានសេចក្តីថាយើងត្រូវធ្វើអំពើបាបហើយសូមខមាទោស រួចហើយធ្វើអំពើបាបទៀតឥតឈប់ ហើយក៏សូមខមាទោសទៀតរាល់ដងដោយសង្ឃឹមថាគេនឹងលើកលែងទោសឲ្យនោះទេ ។ អល់ឡោះហ្ទ៏ﷻនឹងលើកលែងទោសឲ្យយើងបើយើងស្តាយក្រោយដោយស្មោះ ។

អ៊ីម៉ាំទី ៥ របស់យើង គឺអ៊ីម៉ាំ មូហាំម៉ាដ់ អាល់-បាកៀរ صلوات الله عليه والسلام មានវចនៈថាអ្នកណាឈប់ធ្វើអំពើបាបទាំងអស់ក្រោយពីបានសូមខមាទោស អ្នកនោះប្រៀបបាននឹងបុគ្គលដែលមិនធ្លាប់បានធ្វើអំពើបាបសោះ ។ តែអ្នកណាដែលនៅតែធ្វើអំពើបាបព្រមនឹងសូមខមាទោស អ្នកនោះជាអ្នកកំប្លែង ក្រមាច់ក្រមើម ។

គេប្រាប់យើងជាញឹកញយឲ្យ "តៅបាស់" ដែលបានធ្វើអំពើបាប ។

តៅបាស់មានន័យថាត្រឡប់វិញ ។ ត្រឡប់ពីអំពើបាបដែលបានសាងហើយដើម្បីមកតាមមាគ៌ាត្រូវក្នុងអនាគត ។ តៅបាស់មិនត្រឹមតែមានន័យថាសូមខមាទោសអល់ឡោះហ្ទ៏ﷻទេ តែមានន័យដែរថាត្រឡប់មករកអល់ឡោះហ្ទ៏ﷻវិញ ។

ពេលតៅបាស់ (ពេលសូមខមាទោសអល់ឡោះហ្ទ៏ﷻ) អ្នកត្រូវ៖

១) ស្តាយក្រោយដោយស្មោះដែលអ្នកបានធ្វើអំពើបាប ។

២) សូមខមាទោសដោយស្មោះ ដោយមានអារម្មណ៍ខ្មាសអៀនដែលបានធ្វើអំពើបាប ។

៣) សន្យាថាឈប់ធ្វើអំពើបាបទៀត និងធ្វើតាមព្រះបញ្ជាអល់ឡោះហ្ជ៏ ។

៤) សូមឲ្យអល់ឡោះហ្ជ៏អាណិតមេត្តា ព្រោះព្រះអង្គ មានព្រះមេត្តាធម៌លើសលុប ។

គេថាយើងត្រូវបួងសួងអល់ឡោះហ្ជ៏ជានិច្ច សូមឲ្យព្រះអង្គជម្រះក្តីយើងក្នុងថ្ងៃជំនុំជម្រះ ដោយផ្អែកលើព្រះធម៌មេត្តារបស់ព្រះអង្គ កុំឲ្យព្រះអង្គជម្រះក្តីយើងដោយផ្អែកលើយុត្តិធម៌របស់ព្រះអង្គ (តុលាការអល់ឡោះហ្ជ៏) ។

មានបុរសម្នាក់ជឿសប់ណាស់ គាត់ជឿជាក់ក្នុងចិត្តថាគាត់ជាមនុស្សត្រង់ ។ គាត់បួងសួងអល់ឡោះហ្ជ៏ សូមឲ្យព្រះអង្គជម្រះក្តីគាត់តាមយុត្តិធម៌របស់ព្រះអង្គ កុំជក្រះក្តីគាត់តាមព្រះមេត្តាធម៌របស់ព្រះអង្គ ។ យប់មួយ បុរសនេះដេកយល់សប្តិឃើញថ្ងៃជំនុំជម្រះ ។ នៅពីមុខគាត់មានជញ្ជីងថ្លឹងទង្វើល្អក្នុងដៃម្ខាងទង្វើអាក្រក់ក្នុងដៃម្ខាងទៀត ។ អ្វីដែលធ្វើឲ្យគាត់ភ្ញាក់ផ្អើលនោះគឺដៃជញ្ជីងដែលដាក់ផ្លែប៉ោមធ្ងន់ជាងដៃជញ្ជីងដែលដាក់ទង្វើល្អ ។ ពេលបុរសនេះសួរចង់ដឹងថាផ្លែប៉ោមនេះមានន័យអ្វី គេបានប្រាប់គាត់ថាថ្ងៃមួយគាត់បានទៅផ្សារ បានភ្លក្សផ្លែប៉ោម ចង់ដឹងថាវាទុំឬនៅក្នុងបំណងទិញវាបើវាត្រូវចិត្តគាត់ តែគាត់មិនបានសូមអនុញ្ញាតពីម្ចាស់ហាងទេ ។ ព្រោះតែបុរសនេះសូមឲ្យអល់ឡោះហ្ជ៏ជម្រះក្តីគាត់តាមយុត្តិធម៌របស់ព្រះអង្គ ផ្លែប៉ោមតែមួយនេះធ្ងន់ជាងទង្វើល្អទាំងអស់របស់គាត់ ។

ចូរចងចាំថា អល់ឡោះហ្ជ៏មានព្រះធម៌មេត្តា មានព្រះករុណាប្រណីលើសលុប ចូរសូមឲ្យព្រះអង្គលើកលែងទោសឲ្យអ្នកជានិច្ច តែចូរអ្នកស្មោះក្នុងចិត្ត ។

# លំហាត់ ១៦

តៅបាស្ញ គឺ... (ចូរសរសេរចម្លើយនៅពីមុខផ្លែព្រួញនីមួយៗ) ។




ចូរគូសមុខព្រួញដើម្បីបង្ហាញខាងដែលធ្ងន់ជាងគេ ។




តើបុរសជឿសប់យល់សប្តិឃើញអ្វី ? ហេតុអ្វី ?

_______________________________________________

_______________________________________________

## មេរៀនទី ១៧

# លើកលែងទោសឲ្យអ្នកដទៃ

អល់ឡោះហ្ជ័ល្លមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាត់-តាក៏ប៊ូន អាយ៉ាស់ ១៤ ថា៖

وَإِن تَعۡفُواْ وَتَصۡفَحُواْ وَتَغۡفِرُواْ فَإِنَّ ٱللَّهَ غَفُورٞ رَّحِيمٌ ١٤

*១៤. បើពួកអ្នកអត់ឱន បំភ្លេចនិងលើកលែងទោសពៃរ៍[ពួកគេ] ពិតណាស់ អល់ឡោះហ្វ៍ទ្រង់លើកលែងទោស ព្រះអង្គមានព្រះមេត្តាករុណាប្រណី ។* (៦៤:១៤)

អាយ៉ាស់នេះចែងប្រាប់យើងថាពេលយើងលើកលែងទោស មិនត្រឹមតែលើកលែងទោសឲ្យគេម្យ៉ាងទេ តែបំភ្លេចកំហុសនិងបិទបាំងកំហុសឲ្យអ្នកដទៃផងដែរ អល់ឡោះហ្ជ័ល្លនឹងធ្វើដូចនេះដែរមកលើខ្លួនយើង ។ ហេតុអ្វីយើងត្រូវបិទបាំងកំហុសឲ្យអ្នកដទៃដែរ ? ពីព្រោះភាសាអារ៉ាប់ប្រើពាក្យ *ក៏ហ្វារ (غَفَرَ)* សម្រាប់ហៅ "លើកលែងទោស" នៅក្នុងអាយ៉ាស់នេះ ។ *ក៏ហ្វារ* មានអត្ថន័យដើមថា *លាក់, បិទបាំង, ការពារ ។* ចូរចងចាំថាអល់ឡោះហ្ជ័ល្លទ្រង់មានព្រះមេត្តាករុណាប្រណី ។

លើកលែងទោសឲ្យគេ គឺឲ្យគេរួចខ្លួនដោយអភ័យឲ្យគេដែលបានធ្វើខុសមកលើខ្លួនអ្នក ។

អល់ឡោះហ្ជ័ល្លមិនត្រឹមតែឲ្យយើងលើកលែងទោសតែម្យ៉ាងទេ តែឲ្យយើងបំភ្លេចចោល គឺបើកផ្លូវឲ្យគេ និងឲ្យយើងបិទបាំង គឺមិននិយាយប្រាប់អ្នកដទៃថាបុគ្គលមានកំហុសនេះបានធ្វើអ្វីខ្លះ នោះផងដែរ ។

អ៊ីម៉ាំទី ១ របស់យើង គឺអ៊ីម៉ាំអាលី صلوات الله عليه والسلام មានវចនៈថាការលើកលែងទោសពិតគឺការលើកលែងទោសនៅក្នុងពេលដែលយើងអាចសងសឹកគេវិញបាន គឺនៅក្នុងពេលដែលយើងមានសិទ្ធិប្រព្រឹត្តតបអ្នកដទៃវិញបាន ដែលបានប្រព្រឹត្តមកលើខ្លួនយើង ។

ហាឌីស្សនេះបញ្ជាក់ប្រាប់យើងថា ពេលដែលយើងលើកលែងទោសឲ្យគេ

ដោយស្មោះអស់ពីចិត្តនោះ គឺពេលដែលយើងមានសិទ្ធិសងសឹកគេវិញតែយើងមិនសងសឹកគេទេ យើងសុខចិត្តលើកលែងទោសឲ្យគេវិញ ។

លើកលែងទោសឲ្យគេគឺបំភ្លេចចោលរឿងដែលបានកើតឡើង មិនរំលឹកឡើងវិញអ្នកដែលធ្វើខុសទេ មិននិយាយប្រាប់អ្នកដទៃនូវកំហុសអ្នកនោះទេ ។

អ៊ីម៉ាំអាលីصلوات الله عليه والسلامមានវចនៈថា៖ "ចូរធ្វើទោសសត្រូវអស់លោកដោយមានសប្បុរសធម៌ ។ ចូរធ្វើល្អចំពោះពួកគេជួសអំពើអាក្រក់ដែលពួកគេបានធ្វើមកលើអស់លោក ។"

# លំហាត់ ១៧

ពេលណាគឺពេលដែលយើងលើកលែងទោសឲ្យគេដោយស្មោះអស់ពីចិត្ត ?

________________________________________________

______________________________________________

ហេតុអ្វីអ្នកត្រូវលើកលែងទោសឲ្យគេ ?

________________________________________________

______________________________________________

តើមានន័យពិតប្រាកដថាអ្វីដែលយើងលើកលែងទោសឲ្យគេនោះ ?

________________________________________________

______________________________________________

ចូរបំពេញហ្គាឌ្វីស្ហខាងក្រោមនេះ គឺ៖

អ៊ីម៉ាំអាលី صلوات الله عليه والسلام មានវចនៈថា៖ "ចូរធ្វើទោសសត្រូវអស់លោកដោយ______ ________ ។ ចូរធ្វើ_____ចំពោះពួកគេជួសអំពើអាក្រក់ដែលពួកគេបានធ្វើមកលើអស់លោក ។"

## មេរៀនទី ១៨

# ភាតរភាព-ឯកភាព

អល់ឡោះហ្ស៍ عزوجل មានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាល់-ហ៊្វូយូរ៉ាត អាយ៉ាស់ ១០ ថា៖

إِنَّمَا ٱلْمُؤْمِنُونَ إِخْوَةٌ فَأَصْلِحُوا۟ بَيْنَ أَخَوَيْكُمْ ۚ وَٱتَّقُوا۟ ٱللَّهَ لَعَلَّكُمْ تُرْحَمُونَ ﴿١٠﴾

*១. បណ្ដាអ្នកមានសទ្ធាជាបងប្អូនគ្នា ។ ដូច្នេះចូរពួកអ្នកផ្សះផ្សាបងប្អូនពួកអ្នកនិងចូរខ្លាចអល់ឡោះហ្វ៍ដើម្បីពួកអ្នកនឹងបានទទួលនូវព្រះមេត្តាប្រណី ។*(៤៩:១០)

អាយ៉ាស់នេះថែងប្រាប់យើងថាមុស្លីមទាំងអស់ជាបងប្អូនគ្នា ថាឲ្យមុស្លីមទាំងអស់គ្នាមើលថែរក្សាគ្នា ។

ព្រះសាស្ដា ﷺ មានព្រះវចនៈថា៖ "មុស្លីមគឺបុគ្គលដែលដៃនិងអណ្ដាតមិនធ្វើឲ្យមុស្លីមម្នាក់ទៀតឈឺចាប់ទេ ។"

ហាឌីស្ហ៍នេះបញ្ជាក់ប្រាប់យើងថា មុស្លីមណាដែលធ្វើឲ្យមុស្លីមម្នាក់ទៀតរងទុក្ខដោយកាយក្ដី (ដោយដៃ) ដោយអារម្មណ៍ក្ដី (ដោយអណ្ដាត, ដោយសម្ដី...) អ្នកនោះមិនមែនមុស្លីមទេ ។

ព្រះសាស្ដា ﷺ ជាអ្នកនាំចូលទ្រឹស្ដីភាតរភាពក្រោយសករាជហ៊ិជ្រ៉ោះត៍ កាលអ្នកស្រុកម៉ាក់កាស់ចាំបាច់ត្រូវចាកចោលផ្ទះសម្បែងនិងទ្រព្យសម្បត្តិ ដើម្បីភៀសខ្លួនទៅកាន់ម៉ាឌីណាស់ ។ ព្រះសាស្ដា ﷺ បានបង្រួបបង្រួមអ្នកស្រុកម៉ាក់កាស់ម្នាក់ៗជាមួយបងប្អូនអ្នកស្រុកម៉ាឌីណាស់ម្នាក់ ដើម្បីនឹងឲ្យពួកគេអាចពឹងពាក់គ្នាបាន ។

អ៊ីស្លាមចាត់ទុកព្រះសាស្ដា ﷺ ជាបិតារបស់មុស្លីមទាំងអស់ ដែលទាក់ទងគ្នានិងរួបរួមគ្នាតាមរយៈសាសនាអ៊ីស្លាម ។ សហគមន៍មុស្លីមទាំងមូលជាគ្រួសារធំមួយ អ្វីដែលសមាជិកគ្រួសារធំនេះធ្វើ ជះឥទ្ធិពលទៅលើសមាជិកឯទៀតរបស់គ្រួសារនេះ ។

ថ្ងៃមួយ មនុស្សមួយក្រុមនៅលើនាវាប្រកែកគ្នា ។ អ្នកខ្លះជឿជាក់ថា ភាតរភាព (ឯកភាព) មិនមានប្រយោជន៍ទេ ម្នាក់ៗអាចធ្វើអ្វីបានតាមចិត្តដោយមិនជាប់ពាក់ព័ន្ធជាមួយអ្នកដទៃទេ ។ បុគ្គលដែលគិតថាយើងត្រូវរស់នៅជាបងប្អូនគ្នា បានទៅកាន់ជ្រុងមួយនៃនាវានោះ ហើយគាត់ចោះទូកនោះ ។ មនុស្សឯទៀតដែលគិតថាភាពជាបងប្អូនគ្នាមិនមានប្រយោជន៍ទេនោះបន្ទោសគាត់ថាឆ្កួត ហើយប្រាប់គាត់ថាបើគាត់នៅតែធ្វើបែបនេះទៀត ទាំងអស់គ្នានឹងលង់ទឹកស្លាប់ ។ បុរសនោះបានឆ្លើយថាពួកគាត់មិនបាច់បារម្ភអំពីទង្វើគាត់ទេ ព្រោះពួកគាត់បានថា ម្នាក់ៗអាចធ្វើអ្វីបានតាមតែចិត្តចង់ដោយមិនបាច់គិតដល់អ្នកដទៃឡើយ ។ មនុស្សទាំងនោះភ្ញាក់ខ្លួនថាបុរសនោះនិយាយត្រូវ ដើម្បីរស់នៅដោយសុខសាន្តជាមួយអ្នកដទៃ គេត្រូវមើលថែរក្សាគ្នាទៅវិញទៅមក ត្រូវរួបរួមគ្នាជាភាតរភាពនីមួយ ។

ចូរចងចាំថាមុស្លីមរាល់គ្នាមានសិទ្ធិមួយលើខ្លួនអ្នក ក្នុងនាមជាបងប្អូនគ្នា យើងទាំងអស់គ្នាឯកភាពគ្នា (គឺជាប់ទាក់ទិនគ្នា) តាមរយៈសាសនាអ៊ីស្លាម ។

# លំហាត់ ១៨

ចូរគូរលើទូកទង្វើរបស់បុរសដើម្បីបង្ហាញថា សហគមន៍នីមួយៗចាំបាច់ឯកភាពគ្នានិងចាំបាច់ជាបងប្អូនគ្នា ។



ចូរបំពេញហាឌីស្សព្រះសាស្តា ﷺ ដោយប្រើរូបភាពខាងក្រោមនេះ ។





ព្រះសាស្តា ﷺ មានព្រះវចនៈថា៖ "មូស្លីមគឺបុគ្គលដែល_______________ _________________________ ។"

## មេរៀនទី ១៩

# ត្រួតពិនិត្យខ្លួនឯង

អល់ឡោះហ្ ﷻ មានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាល់-គ្ហីយ៉ាម៉ាស់ អាយ៉ាស់ ២ ថា៖

وَلَآ أُقۡسِمُ بِٱلنَّفۡسِ ٱللَّوَّامَةِ ۝٢

*២. អញសូមស្បថចំពោះព្រលឹងដែលស្ដីបន្ទោសខ្លួនឯង!* (៧៥:២)

អាយ៉ាស់នេះចែងប្រាប់យើងថា មានកន្លែងមួយនៅក្នុងវិញ្ញាណយើងដែលស្ដីបន្ទោសខ្លួនឯងឥតឈប់ កន្លែងនេះសំខាន់ណាស់ដល់ថ្នាក់អល់ឡោះហ្ ﷻ ស្បថក្នុងនាមវា ។

អ្វីទៅវិញ្ញាណនោះ ដែលស្ដីបន្ទោសខ្លួនឯង ?

នោះគឺសតិសម្បជញ្ញៈ គឺប៉ែកមួយនៃខ្លួនយើងដែលបង្កើតនូវអារម្មណ៍ដឹងកំហុសក្នុងខ្លួនយើងពេលយើងធ្វើអំពើអាក្រក់នីមួយ ។ ត្រួតពិនិត្យខ្លួនឯងគឺស្ដាប់សតិសម្បជញ្ញៈនេះ ។ បើអ្នកមិនអើពើសតិសម្បជញ្ញៈអ្នកទេ ប្រាកដជានឹងមានពេលមួយដែលអ្នកនឹងលែងឮសតិសម្បជញ្ញៈនោះ អំណឺះតទៅ ពេលដែលអ្នកនឹងធ្វើប្រការអាក្រក់នីមួយអ្នកនឹងពុំមានអារម្មណ៍ថាមានកំហុសទេ ។

ថ្ងៃមួយ ព្រះសាស្ដា ﷺ យើងបានធ្វើដំណើរជាមួយបណ្ដាសាវកព្រះអង្គ ﷺ លុះបានដល់កន្លែងគ្មានមនុស្សនៅ ពុំមានរុក្ខជាតិដុះទេនៅទីនោះ ។ ព្រះសាស្ដា ﷺ បានឲ្យសាវកទៅរកឱស ។ ពួកសាវកបានតបថានឹងរកឱសពុំបានទេនៅកណ្ដាលវាលគ្មានអ្វីដុះទេនោះ ។ ព្រះសាស្ដា ﷺ បានប្រាប់ពួកគេឲ្យសាកល្បងទៅដើររក ។ ពួកសាវកក៏ទៅដើររក ហើយរកបានតែបន្តិចបន្តួច ។ មិនយូរប៉ុន្មានក៏រកបានឱសមួយគំនរធំនៅពីមុខព្រះសាស្ដា ﷺ ។ ព្រះសាស្ដា ﷺ បានប្រាប់ពួកសាវកថាពួកគាត់អាចរាវរកបាបបានគរគោកយ៉ាងងាយដូចនេះដែរ ។ ព្រះសាស្ដា ﷺ ក៏បានបង្រៀនពួកសាវកឲ្យចេះដឹងការត្រួតពិនិត្យខ្លួនឯង ។

ដូចឱសដែលគេអាចរកបានគរគោក ទោះបីគេមើលវាមិនឃើញពីដំបូងក៏ដោយនោះដែរ បាបរបស់មនុស្សមិនងាយមើលឃើញទេ តែបើគេស្វះស្វែងរក ហើយប្រមូលផ្តុំបាបដែលរកឃើញនោះ គេនឹងឃើញថាបញ្ជីកត់ត្រាបាបទាំងនោះវែងទៅៗ ។

យើងត្រូវពិនិត្យពិច័យខាងក្នុងខ្លួនយើង រុករកបញ្ជីវែងនោះពេលដែលយើងអាចសូមខមាទោសបាននៅឡើយ វាប្រសើរជាងសូមខមាទោសនៅក្នុងថ្ងៃជំនុំជម្រះ ពេលដែលហួសពេលមិនអាចធ្វើអ្វីបាន ។

អ្នកត្រូវកាន់ទម្លាប់ពិនិត្យពិច័យខ្លួនឯងរៀងរាល់ថ្ងៃ (ពេលយប់ឬក្រោយស្វ៏ឡាត់រួច) អ្នកត្រូវគិតដល់ពេលថ្ងៃ ដល់ទង្វើទាំងអស់ដែលអ្នកបានធ្វើក្នុងពេលថ្ងៃនោះ ។ តើអ្នកបានធ្វើប្រការល្អណាខ្លះ ? បើពុំបានធ្វើប្រការល្អទេ ចូរអ្នករិះគិតរកប្រការល្អដែលអ្នកអាចធ្វើបានក្នុងថ្ងៃបន្ទាប់ ។ តើអ្នកបានធ្វើប្រអាក្រក់ណាខ្លះ ? តើអ្នកនឹងកែខៃសងប្រការអាក្រក់នោះដូចម្តេច (តៅបាស្ង) ?

# លំហាត់ ១៩

ហេតុអ្វីព្រះសាស្ដាﷺបានឈប់កនៅន្លែងគ្មានមនុស្សនៅ គ្មានអ្វីជុះ ?



តើព្រះអង្គﷺបានឲ្យបណ្ដាសាវកព្រះអង្គﷺដើរប្រមូលអ្វី ? ហេតុអ្វី ?

តើព្រះអង្គﷺចង់បង្រៀនអ្វីឲ្យបណ្ដាសាវកព្រះអង្គﷺ ?

ហេតុអ្វីការត្រួតពិនិត្យខ្លួនឯងជាប្រការសំខាន់ធំ ?

## មេរៀនទី ២០

# របៀបធ្វើដំណើរ

ព្រះអំណោយមួយ ក្នុងចំណោមព្រះអំណោយយ៉ាងច្រើន ដែលអល់ឡោះហ្ ﷻបានព្រះរាជទានឲ្យព្រះសាស្តាស៊ូឡៃម៉ាន عليه السلام នោះ គឺព្រះអង្គ عليه السلام អាចគ្រប់គ្រងខ្យល់បាន ។ ព្រះអង្គ عليه السلام អង្គុយលើព្រំហើយបញ្ជាខ្យល់ឲ្យនាំព្រះអង្គ عليه السلام ទៅកន្លែងនីមួយដែលព្រះអង្គ عليه السلام ចង់ទៅ ។

ថ្ងៃមួយ ពេលព្រះសាស្តាស៊ូឡៃម៉ាន عليه السلام កំពុងអង្គុយលើព្រំហោះ ដឹកនាំដោយខ្យល់ មានបុរសជឿសប់ចិត្តម្នាក់ឃើញព្រះអង្គ عليه السلام គាត់បានថា៖ "សូមថ្វាយសេចក្តីរុងរឿងចំពោះអល់ឡោះហ្ ﷻ ដែលបានព្រះរាជទាន[អំណាច]នេះឲ្យស៊ូឡៃម៉ាន عليه السلام ។" អល់ឡោះហ្ ﷻទ្រង់សព្វព្រះហឫទ័យការសើចសរសើរនេះណាស់ ព្រះអង្គ ﷻបានចាត់បញ្ជូនទេវតាមួយអង្គទៅជួបព្រះសាស្តាស៊ូឡៃម៉ាន عليه السلام ឲ្យប្រាប់ព្រះអង្គ عليه السلام ថាមានមនុស្សម្នាក់បានលើកតម្កើងព្រះអង្គ ﷻ ដោយវាចាបេយ្យភាព ថាព្រះអង្គ ﷻទ្រង់រីករាយចំពោះអាកប្បកិរិយានេះណាស់ ។ ព្រះសាស្តាស៊ូឡៃម៉ាន عليه السلام បានបកក្រោយវិញ ទៅរកបុរសនោះដើម្បីចង់ដឹងថាគាត់បានថាអ្វី ។ បុរសនោះក៏បានប្រាប់ព្រះអង្គ عليه السلام ។

អល់ឡោះហ្ ﷻមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាស់-ស៊ុក្រុហ្វ អាយ៉ាស់ ១៣ ថា៖

سُبْحَٰنَ ٱلَّذِى سَخَّرَ لَنَا هَٰذَا وَمَا كُنَّا لَهُۥ مُقْرِنِينَ ﴿١٣﴾

*១៣. សូមថ្វាយសេចក្តីរុងរឿងចំពោះព្រះ ដែលបានចញ្ចុះបញ្ចូលអ្វីទាំងនេះឲ្យអស់ទូលព្រះបង្គំជាខ្ញុំ អស់ទូលព្រះបង្គំជាខ្ញុំមិនមានសមត្ថភាពធ្វើបែបនេះបានទេ ។* (៤៣:១៣)

អាយ៉ាស់នេះចែងប្រាប់យើងថា សេចក្តីរុងរឿងជាកម្មសិទ្ធិរបស់អល់ឡោះហ្ ﷻដែលបានព្រះរាជទានអំណាចគ្រប់គ្រងវត្ថុខ្លះឲ្យយើង បើពុំមានព្រះគុណនេះទេ

យើងពុំមានសមត្ថភាពធ្វើដូចនេះបានទេ ។ ដូច្នេះហើយបានជាគេឲ្យសូត្រអាយ៉ាស់នេះមុនធ្វើដំណើរ ពីព្រោះដោយសារតែព្រះគុណអល់ឡោះហ៊្ជَلَّ وَعَزَّបានជាយើងមានមធ្យោបាយដឹកជញ្ជូនដ៏អស្ចារ្យ ។

មានប្រការច្រើនទៀតដែលយើងគប្បីធ្វើមុននឹងធ្វើដំណើរ គឺ៖

-ធ្វើស្វ៉ូឡាតុ្ហាកៀះត៍ ។

-ចេញពីផ្ទះដោយដើរពីក្រោមគួរអាន ។

-យកជាប់នឹងខ្លួនពាក់កណ្តាលស៊ូរ៉ោះត៍ អាល់-អ៊ិះខ៍ទ្បាស្វ៍ ទុកពាក់កណ្តាលទៀតនៅឯផ្ទះ (គេថាទាំងពីរពាក់កណ្តាលនេះនឹងជួបគ្នាវិញ) ។

-សូត្រអាយ៉ាស់ព្រះគម្ពីរគួរអានដែលយើងបានថាខាងលើនេះ (៤៣:១៣) ។ (ហ្ពាឌីស្ហ អ៊ីមុាំ អុ្ាលី អារ-រីជ្ហ صلوات الله عليه والسلام)

## លំហាត់ ២០

ចូរទន្ទេញអាយ៉ាសុ់តទៅនេះ ហើយសរសេរសម្រាយវា ។




តើអាយ៉ាសុ់នេះត្រូវដកស្រង់មកពីសូរ៉ោះតុ៍អ្វី ?

---

នៅពីក្រោមមធ្យោបាយដឹកជញ្ជូនខាងក្រោមនេះ ចូរសរសេរប្រការដែលអ្នកត្រូវធ្វើមុននឹងចេញដំណើរ ។









*Sources:*
imamia.org
shia974.fr
madressa.net
page-borders.com
openclipart.org